**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសំរាម នៅរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ភ .រ៉ុន ជូឌី**
**ទ្រី ច័ណ្ណឌី**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងសំរាម នៅរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ភ.រ៉ុន ជូឌី**
**ទ្រី ច័ណ្ណឌី**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **រ៉ុន ដូឌី** និងខ្ញុំបាទឈ្មោះ **ទ្រី ច័ណ្ណឌី** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។សូមថ្លែងអំណរគុណចំពោះ ៖

កូនសូមសម្តែងនូវមហាកត្តញ្ញូតាធម៌ជាអនេកកប្បការ ចំពោះ **លោកឪពុកនិងអ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត និងខិតខំបីបាច់ថែរក្សាចិញ្ចឹមរូបកូនតាំងពីក្នុងផ្ទៃ រហូតដល់កូនក្លាយជាយុវជនយុវតីពេញរូបពេញរាង ព្រមទាំងទទួលបានការអប់រំទូន្មានតាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ ព្រះគុណដ៏មហាបវរនេះគឺធ្វើអោយកូនចងចាំ និងគ្មានអ្វីអាចបំភ្លេចបានឡើយ។ កូនសូមលើកហត្ថប្រណម្យគោរពប្រណិប័តន៍ផ្ញើរស្នាដៃនេះ ជូនចំពោះលោកទាំងពីរជាទីគោរពដ៏ខ្ពង់ខ្ពស់។

សូមគោរពចំពោះ ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** ព្រមទាំងសាកលវិទ្យាធិការរងព្រឹទ្ធបុរស អស់លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពស់ ព្រមទាំងបានជួយតម្រង់ទិសដល់យើងខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ជាពិសេសសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **ឃុ តូនី** ដែលបានចំណាយពេលវេលាទាំងកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ដោយបានណែនាំអំពីអត្ថន័យ ខ្លឹមសារ ឃ្លោងឃ្លា និងផ្តល់គំនិតល្អៗ សម្រាប់តាក់តែង រៀបរៀង អត្ថបទសារណានេះ ចាប់តាំងពីដំណាក់កាលនៃការរៀបរៀងចាប់ផ្តើម រហូតដល់បានសម្រេចជាស្ថាពរ។

ជាបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរ សិរីមង្គលបវរមហាប្រសើរ កើតមានចំពោះលោកអ្នកមានគុណ បងប្អូន សាច់ញាតិ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ ព្រមទាំងក្រុមគ្រួសារឱ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទស្តីពី **ការគ្រប់គ្រងសំរាម នៅរាជធានីភ្នំពេញ** ដែលមានលោកសាស្ត្រា **យូ តូនី** ជាសាស្ត្រាចារ្យដឹកនាំ ដើម្បីយកមកធ្វើការ សិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់រដ្ឋបាលសាធារណៈនេះ។

ការសម្រេចជ្រើសរើសយកប្រធានបទខាងលើ មកសិក្សាជ្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារយើងខ្ញុំយល់ឃើញថា វាពិតជាមានសារៈសំខាន់ណាស់សម្រាប់បរិស្ថាន ដើម្បីជួយបណ្តុះគំនិតដល់អ្នកដែលបានអាននូវអត្ថបទមួយនេះ ឱ្យមានចិត្តស្រលាញ់ និងជួយការពារបរិស្ថានឱ្យបានល្អ ដើម្បីជាប្រយោជន៍ដល់អ្នកអានផ្ទាល់ និងអ្នកដែលរស់នៅក្នុងសង្គមផងដែរ។

ការសិក្សាស្រាវជ្រាវអត្ថបទមួយនេះ ត្រូវបានចាប់ផ្តើមឡើងដោយការសិក្សា តាមរយៈឯកសារច្បាប់មួយ ចំនួនដែលពាក់ព័ន្ធនឹងបរិស្ថាន ការប្រមូលពត៌មានតាមរយៈកាសែត ការចុះទៅស្រាវជ្រាវដោយផ្ទាល់នៅក្រសួងបរិស្ថាន និងនៅក្រុមហ៊ុនស៊ីនទ្រី ព្រមទាំងការសាកសួរយោបល់អំពីនីតិវិធីក្នុងការដោះស្រាយបញ្ហារបស់មន្ត្រីដែលបម្រើការនៅទីនោះ ដើម្បីយកមកច្របាច់បញ្ចូលគ្នា ក្នុងគោលបំណងឆ្លុះបញ្ចាំងអោយឃើញនូវបញ្ហាប្រឈម ហេតុផល និងចន្លោះខ្វះខាតមួយចំនួនដែលកើតមានចំពោះបរិស្ថាន ក៏ដូចជាការគ្រប់គ្រងសំរាមផងដែរ។

យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ នឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់មិត្ត និស្សិត បញ្ញាវន្ត ដែលមានបំណងចង់សិក្សាស្វែងយល់ពីការគ្រប់គ្រង ព្រមទាំងនីតិវិធី និងដំណោះស្រាយ បញ្ហាដែលទាក់ទងនិងសំរាម។ យើងខ្ញុំសង្ឃឹមទៀតថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយទៅជាឯកសារមួយដែលអាចចូលរួមចំណែក និងជំរុញឱ្យបរិស្ថានកាន់តែមានភាពល្អប្រសើរ។

ជាចុងក្រោយ ទោះបីជាយើងខ្ញុំមានការខិតខំសិក្សាស្រាវជ្រាវ និងត្រួតពិនិត្យយ៉ាងម៉ត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណាមួយនេះនៅតែមានចន្លោះខ្វះខាត ដូចនេះ យើងខ្ញុំទាំងពីរនាក់រងចាំទទួលយកការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិត និងអ្នកអានទាំងអស់ដើម្បីកែលម្អសារណាមួយនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ................................................ ១

## ជំពូកទី ១

## ស្ថានភាពទូទៅ

១.១. ប្រវត្តិនៃការគ្រប់គ្រងសំរាម ................................................ ៤

១.២. និយមន័យ ................................................ ៦

១.៣. ប្រភពនៃសំរាម ................................................ ៧

១.៣.១. ផ្ទះបាយ ................................................ ៧

១.៣.២. ពាណិជ្ជកម្ម ................................................ ៨

១.៣.៣. ឧស្សាហកម្ម ................................................ ៨

១.៤. ប្រភេទនៃសំរាម ................................................ ៨

១.៤.១. ប្រភេទស្ងួត ................................................ ៨

១.៤.២. ប្រភេទសើម ................................................ ៩

១.៥. ច្បាប់ និងគោលការណ៍នានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម ................................................ ៩

១.៥.១. អនុក្រឹត្យ និងប្រកាសស្តីពីការគ្រប់គ្រងសំណល់រឹង ................................................ ៩

១.៥.២. អនុក្រឹត្យ និងប្រកាសស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ................................................ ១០

## ជំពូកទី ២

## ស្ថាប័នផ្សេងៗពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម

២.១. ស្ថាប័នរដ្ឋដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្ត ................................................ ១៣

២.១.១. ក្រសួងបរិស្ថាន ................................................ ១៣

២.១.២. ក្រសួងមហាផ្ទៃ ................................................ ១៣

២.១.៣. មន្ទីរបរិស្ថាន ................................................ ១៤

២.១.៤. រដ្ឋបាលរាជធានី ................................................ ១៥

២.១.៥. រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ................................................ ១៦

២.២. ស្ថាប័នឯកជន (ក្រុមហ៊ុនស៊ីនទ្រី) ................................................ ១៧

២.២.១. រចនាសម្ព័ន្ធដឹកនាំរបស់ក្រុមហ៊ុន ................................................ ១៧

២.២.២. ផ្នែកទទួលបន្ទុកផ្សេងៗរបស់ក្រុមហ៊ុន ........................................................ ១៧

## ជំពូកទី ៣

## ដំណើរការនៃការគ្រប់គ្រងសំរាម (ក្រុមហ៊ុនស៊ីនទ្រី)

**៣.១. ការប្រមូលសំរាម** ........................................................ ២១
៣.១.១. បុគ្គលិក ........................................................ ២១
៣.១.២. សម្ភារៈ ........................................................ ២២
**៣.២. ការគិតថ្លៃសេវា** ........................................................ ២២
៣.២.១. សេវាលើការប្រមូល សម្អាត និងដឹកជញ្ជូន ........................................................ ២២
៣.២.២. ការផាកពិន័យ ........................................................ ២៣
**៣.៣. បញ្ហាប្រឈម និងដំណោះស្រាយ** ........................................................ ២៦
៣.៣.១. បញ្ហាប្រឈម ........................................................ ២៦
៣.៣.២. ដំណោះស្រាយ ........................................................ ២៧
**សេចក្តីសន្និដ្ឋាន** ........................................................ ២៩
**អនុសាសន៍** ........................................................ ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសដ៏ចំណាស់មួយ ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាប្រទេសកំពុងអភិវឌ្ឍន៍មួយផងដែរ។ ក្រោយពីសង្គ្រាមរ៉ាំរ៉ៃនៅក្នុងប្រទេសបានបញ្ចប់ ប្រទេសកម្ពុជាចាប់ផ្តើមមានសន្តិសុខស្ថេរភាព ព្រមទាំងរីកចម្រើនស្ទើរគ្រប់វិស័យ។ នៅក្នុងពេលដែលវិស័យសេដ្ឋកិច្ច និងទេសចរណ៍មានការរីកចម្រើនយ៉ាងគំហុក ការគ្រប់គ្រងសំរាម គឺជាបញ្ហាប្រឈមដ៏សំខាន់មួយដល់បរិស្ថាន ព្រមគ្នានឹងបញ្ហាសំខាន់ៗផ្សេងទៀតដូចជាបញ្ហាអនាម័យជាដើម។ ទន្ទឹមនិងនេះក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានចាប់ផ្តើមចែងជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាច្រើន ដែលមានដូចជា រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យ សារាចរ ប្រកាស សេចក្តីជូនដំណឹង ដែលបានបញ្ញត្តិយ៉ាងច្បាស់អំពីការត្រួតពិនិត្យ ការគ្រប់គ្រង និងដោះស្រាយលើបញ្ហាសំរាម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ទោះបីជាមានច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើន ស្តីពីការគ្រប់គ្រងសំរាមក្តី តែហាក់ដូចជាមិនសូវមានភាពឆាប់រហ័សទៅលើការដោះស្រាយបញ្ហាសំរាមនោះទេ។ [1] ហើយបញ្ហាសំរាមនេះផងដែរ បានក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនកំពុងចោទឡើងគួរអោយកត់សំគាល់ជារៀងរាល់ថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាទូទៅត្រូវបានលើកយកមកជជែកទាំងនៅលើទំព័រសាព័ត៌មាន តាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងកិច្ចពិភាក្សាគោលនយោបាយ។[2] យើងសង្កេតឃើញថា បញ្ហាទាក់ទងនឹងសំរាមកើតមានជារៀងរាល់ថ្ងៃ ដែលបង្កនូវផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនសព្វថ្ងៃ។ ចំណែកឯ យន្តការនៃការដោះស្រាយនៅមានកម្រិត ទាំងយន្តការដោះស្រាយតាមបច្ចេកទេស និងយន្តការដោះស្រាយតាមផ្លូវច្បាប់។ ដោយមើលឃើញពីស្ថានភាពបែបនេះទើបធ្វើអោយមានចំណោទមួយ ចំនួនលើកឡើងថា៖ តើសំរាមមានប្រភពមកពីកន្លែងណាខ្លះ? មានប៉ុន្មានប្រភេទ? តើស្ថាប័នពាក់ព័ន្ធណាខ្លះមានសមត្ថកិច្ចក្នុងការគ្រប់គ្រង? ហើយតើត្រូវមានយន្តការបែបណា ដើម្បីកាត់បន្ថយ ឬ បញ្ឈប់នូវការ

[1] https://khmer.voanews.com/a/public-littering-habit-still-a-concern/3598344.html (ចូលទស្សនានៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩)

[2] របាយការណ៍លទ្ធផលនៃការអង្កេតស្តីពីការអនុវត្តការគ្រប់គ្រងសំរាម និងសំណល់រឹងនៅរដ្ឋបាលក្រុង ស្រុក ,ខែកញ្ញា ២០១៥

កើតមានសំរាមនៅក្នុងបរិស្ថានឱ្យកាន់តែមានប្រសិទ្ធភាព?ដែលទាំងបីចំណុចនេះ នឹងក្លាយជាចំណោទបញ្ហាក្នុងការស្រាវជ្រាវនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងខ្ញុំមានបំណងពន្យល់អំពីប្រភេទនៃសំរាម ស្ថាប័នពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសំរាម និងយន្តការដោះស្រាយបញ្ហាសំរាម ដោយរួមបញ្ចូលទាំងការដោះស្រាយតាមបែបបច្ចេកទេស និងព្រមទាំងការដោះស្រាយទៅតាមផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជាផងដែរ ដើម្បីជាឯកសារជំនួយបន្ថែម ទៅដល់អ្នកចង់សិក្សាលើបញ្ហានេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះសារណានេះ យើងខ្ញុំសូមលើកយកតែប្រភព និងប្រភេទនៃសំរាម (សំណល់រឹង) តួនាទី និងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ និងដំណើការនៃការគ្រប់គ្រង និងយន្តការដោះស្រាយទាក់ទងនឹងបញ្ហានេះ យកមកសិក្សា។ ចំពោះយន្តការដោះស្រាយ យើងខ្ញុំនឹងសិក្សាអំពីយន្តការរបស់ក្រសួងបរិស្ថាន និងក្រុមហ៊ុនស៊ីនទ្រីលើបញ្ហាសំរាមនេះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវនេះ

ការស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះយើងខ្ញុំ និងអ្នកសិក្សាដទៃទៀត ដើម្បីជាការបំពេញបន្ថែម នូវចំនេះដឹង ក្រៅពីការសិក្សា ក្នុងម៉ោងសិក្សានៅសាលា និងសៀវភៅផ្សេងៗទាក់ទងនឹងការគាំពារបរិស្ថាន រួមចំណែកក្នុងការកាត់បន្ថយសំរាម ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីស្រាវជ្រាវសរសេរចងក្រងសារណានេះ ចំពោះឯកសារ យើងខ្ញុំបានធ្វើការស្រាវជ្រាវលើគ្រប់ឯកសារដែលពាក់ព័ន្ធដូចជា៖

- ច្បាប់
- អនុក្រឹត្យ
- ប្រកាស
- សារាចរណែនាំ
- សេចក្តីជូនដំណឹង
- កាសែត
- និងតាមរយៈប្រព័ន្ធអ៊ិនធើណែតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ យើងខ្ញុំបានធ្វើការបែងចែកជាបីជំពូករួមមាន៖

**ជំពូកទី ១ ស្ថានភាពទូទៅ**

**ជំពូកទី ២ ស្ថាប័នផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម**

**ជំពូកទី ៣ ដំណើរការនៃការគ្រប់គ្រងសំរាម(ក្រុមហ៊ុនស៊ីនទ្រី)**

ចំពោះខ្លឹមសារ ដែលទាក់ទងទៅនឹងចំណោទបញ្ហាដែលចោទឡើង ក៏ដូចជារាល់ចំណុចដែលបានលើកឡើងខាងលើ យើងខ្ញុំនឹងធ្វើការអត្ថាធិប្បាយខ្លឹមសារនៅក្នុងអត្ថបទស្រាវជ្រាវនេះ។

# ជំពូកទី ១

# ស្ថានភាពទូទៅ

# ជំពូកទី ១ ស្ថានភាពទូទៅ

រាជធានីភ្នំពេញ គឺជាទីក្រុងធំជាងគេបំផុត និងជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌល សន្តិសុខ នយោបាយ សេដ្ឋកិច្ច សម្បត្តិវប្បធម៌ និងការទូត ដែលមានហេដ្ឋារចនាសម្ព័ន្ធប្រៀបដូចជាសរសៃឈាម លម្អដោយសួនច្បារតាមដងវិថី និងភ្លើងចម្រុះពណ៌នាពេលរាត្រី។ រាជធានីភ្នំពេញមានផ្ទៃដី សរុប៦៩,២៤៦គីឡូម៉ែតក្រឡា មានប្រជាជន ១,៤៧០,៣០៣ នាក់និងមាន ខណ្ឌ ចំនួន១២ (២០១៨ឆ្នាំ)និងបានបំបែកបន្ថែមចំនួន ២ខណ្ឌបន្ថែមទៀត ១គឺខណ្ឌកំបូល បំបែកចេញពីខណ្ឌពោធិ៍សែនជ័យ ២គឺខណ្ឌបឹងកេងកងបំបែកចេញពីខណ្ឌចំការមន សរុបគឺ១៤ខណ្ឌ (២០១៩ឆ្នាំ)ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន នៅរាជធានីភ្នំពេញ ផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងរដ្ឋបាល ទទួលបាននូវគុណភាពនៃការគ្រប់គ្រង រក្សាឱ្យបាននូវស្ថេរភាព សុវត្ថភាព សាធារណៈ ជំរុញឱ្យមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់ រហ័ស។[3] ស្របគ្នាជាមួយនឹងកំណើនផ្ទៃដី កំណើនសេដ្ឋកិច្ច និងកំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ បរិមាណសំរាមក៏មានការកើនឡើងយ៉ាងខ្លាំងផងដែរ ដែលជាបញ្ហាប្រឈមចំពោះមុខសម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ដោយក្នុងនោះតម្រូវឱ្យមានការពង្រីកបន្ថែមទៀតនូវការផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់ឱ្យបានល្អ។

ជាមួយគ្នានេះផងដែរ ចំពោះការអនុវត្តការងារទាំងអស់នេះ សាលារាជធានីភ្នំពេញ បានផ្តល់សិទ្ធិឱ្យក្រុមហ៊ុនស៊ីនទ្រី ជាអ្នកធ្វើការសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាមផ្តាច់មុខនៅរាជធានីភ្នំពេញនេះ លើកលែងតែសំរាមពីរមុខដែលមានស្ថាប័នពីរផ្សេងទៀតជាអ្នកប្រមូល គឺសំរាមវេជ្ជសាស្ត្រ ប្រមូលដោយការិយាល័យគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ នៃទីស្នាក់ការកាកបាទក្រហមកម្ពុជា និងមួយផ្នែកទៀតគឺសំរាមឧស្សាហកម្ម ប្រមូលដោយក្រុមហ៊ុន សារ៉ុមជ្រៃឌីង។ រីឯក្រុមហ៊ុនស៊ីនទ្រី ទទួលខុសត្រូវលើសំណល់រឹង បាយ និងផ្ទះ សំរាម (ង្គកាកសំណល់សេរីរា) តម្រូវគឺ ហើយការទូទាត់ថ្លៃសេវាត្រឡប់ទៅក្រុមហ៊ុនស៊ីនទ្រីវិញឱ្យបណ្តាលក្រុម គ្រប់ស្ថាប័នហ៊ុនឯកជន អង្គការនានា ផ្ទះប្រជាពលរដ្ឋទូទៅ និងទីតាំងដែលប្រកបអាជីវកម្មគ្រប់ប្រភេទ ត្រូវបង់សេវាជាមួយវិក្កយបត្រអគ្គិសនី នៃអគ្គិសនីកម្ពុជា ទៅតាមតារាងកំណត់កម្រៃសេវាគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ។

## ១.១. ប្រវត្តិនៃការគ្រប់គ្រងសំរាម

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលធ្លាប់បានឆ្លងកាត់សង្គ្រាមជាច្រើនលើកច្រើនសារ

[3] www.phnompenh.gov.kh

ទាំងសង្គ្រាមស៊ីវិល និងសង្គ្រាមជាយដែន។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រជាជនដែលត្រូវបានជំលៀសចេញពីភ្នំពេញ ក៏បានវិលត្រឡប់មកកាន់ទីលំនៅចាស់ៗរបស់ខ្លួនវិញ ជាលើកដំបូងដែលភ្នំពេញមានសំឡេងលាន់ឮកងរំពង់ឡើងវិញ ដោយសារប្រជាជននាំគ្នាប្រមូលផ្តុំនៅទីប្រជុំជនដើម្បីជាទីកន្លែងដោះដូរទំនិញ និងប្រកបរបររកស៊ីចញ្ចឹមជីវិត។[4]

ក្នុងស្ថានភាពទប់ស្កាត់ការវិលត្រឡប់មកនៃរបបប្រល័យពូជសាសន៍ផង និងការកសាងប្រទេសផង រដ្ឋអំណាច និងប្រជាជនបានរួមគ្នា ពុះពារជំនះលើការលំបាកគ្រប់បែបយ៉ាងជាបន្តបន្ទាប់ និងបានកែប្រែសោភ័ណភាពរាជធានីភ្នំពេញឱ្យកាន់តែស្រស់បំព្រងគួរជាទីមោទនៈ។ ប្រព័ន្ធរដ្ឋបាលនៃការគ្រប់គ្រងក៏ចាប់ផ្តើមមានកំណើតឡើងវិញបន្តិចម្តងៗ ដែលជាហេតុធ្វើឱ្យមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធរាជធានីភ្នំពេញឱ្យមានភាពស្រស់បំព្រង បន្តិចម្តងៗជាលំដាប់។ ភ្នំពេញកាន់តែស៊ីវិល័យ ប្រជាជនកាន់តែមានការចាប់អារម្មណ៍មករស់នៅកាន់តែច្រើន ការចំណាកស្រុកស្រែចំការមកកាន់ទីក្រុង ធ្វើឱ្យរាជធានីភ្នំពេញមានកំណើនប្រជាជនយ៉ាងខ្លាំងសន្ធឹកសន្ធាប់ ជាកត្តាមួយដែលជំរុញឱ្យ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបង្កើតនូវក្រសួងស្ថាប័នជាច្រើនវិស័យដើម្បីគ្រប់គ្រងស្ថានភាពសង្គមទៅតាមសភាពការ ក្នុងនោះក្រសួងបរិស្ថាន គឺជាក្រសួងមួយក្នុងចំណោមក្រសួងជាច្រើនទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ដែលមានមុខងារនិងតួនាទី ដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថានការអភិរក្សជីវចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព ដូចមានចែងក្នុង អនុក្រឹត្យ លេខ១៣៥ អនក្រ. ២០១៦ខែកក្កដា ឆ្នាំ ០៥បក ចុះថ្ងៃទី ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន។[5]

ប៉ុន្តែយោងតាមអនុក្រឹត្យលេខ៣៦ ស្តីពីការគ្រប់គ្រងសំណល់រឹង បានបញ្ជាក់អោយឃើញពីការផ្ទេរការគ្រប់គ្រងសំរាម(សំណល់រឹង)អោយទៅរដ្ឋបាលរាជធានីភ្នំពេញ (សាលារាជធានីភ្នំពេញ) ជាអ្នកគ្រប់គ្រង។ ដោយរូបជាប្រធាន១ សាលារាជធានីភ្នំពេញ មានអភិបាលនៃគណៈអភិបាលជាសេនាធិការគ្រប់គ្រងលើទីចាត់ការ រូប៦ ក្រុមប្រឹក្សាអមដោយអភិបាលរង ឬ ការិយាល័យល់ និងបរិស្ថានមួយដែលមានផ្សេងៗនៃមុខងាររដ្ឋបាល។ ក្នុងនោះមានទីចាត់ការគ្រប់គ្រងសំណការិយាល័យ២ គឺ ការិយាល័យគ្រប់គ្រងសំណល់ និងការិយាល័យបច្ចេកទេស និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន។ ដូច្នេះហើយដើម្បីគ្រប់គ្រងសំរាម ឬ សំណល់រឹងនៅរាជធានីភ្នំពេញបាន លុះត្រាតែចុះកិច្ចសន្យា និងមានការអនុញ្ញាតពីសាលារាជធានីជាមុនសិនទើបអាចធ្វើទៅបាន។

---

4 www.phnompenh.gov.kh (ចូលទស្សនាចុងក្រោយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩)

5 www.moe.gov.kh/about-moe (ចូលទស្សនាចុងក្រោយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩)

ដោយឡែកក្រុមហ៊ុនស៊ីនទ្រី ជាក្រុមហ៊ុនមួយមានមុខងារសម្អាត ប្រមូល ដឹកជញ្ជូន និង ទុកដាក់សំរាម ឬ សំណល់រឹងនៅរាជធានីភ្នំពេញ ប្រៀបបាននឹងសេនាធិការរបស់ក្រសួងបរិស្ថាន ដូច្នោះដែរ ប៉ុន្តែវាគឺជាក្រុមហ៊ុន ស្វយ័ត្តដាច់ដោយឡែកពីរដ្ឋ គឺមានរចនាសម្ព័ន្ធច្បាស់លាស់ និង មានការគ្រប់គ្រងរដ្ឋបាលមួយដោយខ្លួនឯង។ [6] បច្ចុប្បន្នក្រុមហ៊ុនស៊ីនទ្រី បានដំណើរការការងារ របស់ខ្លួនអស់រយៈពេល១០ឆ្នាំជាងមកហើយ គឺចាប់តាំងពីខែសីហា ឆ្នាំ២០០២មកម្លះ ដែលបានចុះ កិច្ចសន្យា អនុញ្ញាតប្រគល់សិទ្ធិគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ពីសាលារាជធានីភ្នំពេញ បន្តពីក្រុមហ៊ុន «PSBK AND DEVELOPMENT COL,TD» ។ [7]

## ១.២. និយមន័យ

- **សំរាមៈ** សំដៅដល់របស់ប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬ បង្កើតពី សកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬ សំណល់គ្រោះថ្នាក់។
- **សំណល់រឹងទីប្រជុំជនៈ** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬ បង្កើតពីសកម្មភាព អាជីវកម្ម ឬ សេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬ សំណល់គ្រោះថ្នាក់។
- **សំណល់រឹងឧស្សាហកម្មៈ** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬ បង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬ សហគ្រាស ដែលមិនមានផ្ទុកសារធាតុពុល ឬ សំណល់គ្រោះ ថ្នាក់។
- **សំណល់គ្រោះថ្នាក់ៈ** សំដៅដល់វត្ថុធាតុរឹង រាវ និងឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្ក ឱ្យមានជំងឺមហារីក ឬ សារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬ ការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភព សំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អាគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និង អាជីវកម្មរ៉ែ។
- **ការទាញយកធនធានៈ** សំដៅដល់សកម្មភាពជម្រើស ឬ ប្រើប្រាស់សំរាម សំណល់រឹង ធ្វើ ជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬ សារប្រយោជន៍នានា។

---

[6] ក្រុមហ៊ុនស៊ិនទ្រី,របាយការណ៍បូកសរុបលទ្ធផលប្រចាំឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩)

[7] កិច្ចសំភាសតំណាង**ក្រុមហ៊ុន ស៊ីនទ្រី** លោក**សឿន សារ៉ន** «ជំនួយការប្រធានការិយាល័យសម្អាតក្រុង»

- **ការកែច្នៃ:** សំដៅដល់សកម្មភាព ឬ ដំណើរការបំបែក ឬ បំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។
- **ការប្រើប្រាស់ឡើងវិញ:** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សាជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬ ការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។
- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬ ដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។
- **ទីលាន:** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬ រៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។
- **ការធ្វើប្រព្រឹត្តកម្ម:** សំដៅដល់សកម្មភាព ឬ វិធានការណ៍នៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលរួមមាន ៖
  ការបន្ថយទំហំ ឬ ក់នៅទីលាន ដូចជាការបរិមាណសំរាម សំណល់រឹងមុនការយកទៅចាដោះបំបែក ការ កិនកម្ទេច ការរំលាយ ឬ ការដកយក ការដុតនៅក្នុងឡ ឬ ទេចចោលកំការរំលាយជាតិពុល សារធាតុគ្រោះថ្នាក់ ឬ ភ្នាក់ងារចម្លងជំងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់ចោលនៅទីលាន។
- **ទីប្រជុំជន:** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរម្យណីយដ្ឋាន មណ្ឌល់កំសាន្ត តំបន់ទេសចរណ៍។
- **ទីតាំង:** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌល ពាណិជ្ជកម្ម។
- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន:** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។[8]

## ១.៣. ប្រភពនៃសំរាម

សំរាមគឺមានលំហូរពីប្រភពបីធំៗ ដែលមានដូចជា ប្រពភពីគេហដ្ឋាន ពាណិជ្ជកម្ម និងឧស្សាហាកម្ម។

### ១.៣.១. ផ្ទះបាយ

[8] អនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

សំរាមដែលចេញមកពីគេហដ្ឋានរបស់ប្រជាពលរដ្ឋ គឺជាសំរាមដែលកើតឡើងដោយជីវភាពប្រចាំថ្ងៃរបស់មនុស្សនៅតាមផ្ទះនីមួយៗ រួមមានការរៀបចំអាហារ សម្ភារៈផ្ទះបាយ ការសម្អាត វាយនភ័ណ្ឌ គ្រឿងសង្ហារឹម ផេះ ក្រដាស និងសំណល់សួនច្បារ។ មួយផ្នែកទៀតមានដូចជាក្រដាស ផ្លាស្ទិច លោហៈ កែវ និងសំណល់គ្រោះថ្នាក់ជាដើម។

**១.៣.២. ពាណិជ្ជកម្ម**

សំរាមដែលមានប្រភពមកពីពាណិជ្ជកម្ម គឺជាសំរាមដែលចេញពីផ្សារ ហាងទំនិញ ការិយាល័យ ភោជនីយដ្ឋាន សណ្ឋាគារ និងបណ្តាលគ្រឹះស្ថានផ្សេងៗ ដែលជាសំណល់ដែលមានលក្ខណៈជាសម្ភារៈសម្រាប់វេចខ្ចប់ សម្ភារៈការិយាល័យ និងសំណល់ជាអាហារជាដើម។ សំរាមពាណិជ្ជកម្មអាចជា សំរាមដែលមានលក្ខណៈចម្លងរោគ និងសំរាមគ្រោះថ្នាក់។

**១.៣.៣. ឧស្សាហកម្ម**

សមាសធាតុនៃសំរាមឧស្សាហកម្ម មានលក្ខណៈខុសៗគ្នា វាអាស្រ័យប្រភេទនៃរោងចក្រឧស្សាហកម្ម ហើយសំរាមឧស្សាហកម្មអាចមានលក្ខណៈស្រដៀងគ្នានឹងសំរាមចេញពីគេហដ្ឋាន និងពាណិជ្ជកម្មដែរ។ សំរាមដែលមានប្រភពចេញពីឧស្សាហកម្មអាចជាប្រភេទសំណល់ដែលចេញពីរោងចក្រសំលៀកបំពាក់ ស្បែកជើង គ្រឿងអេឡិចត្រូនិច និងអាចជាមណ្ឌលសុខភាពដែលទាក់ទងនឹងការផលិត ឬ ទីពិសោធន៍ឱសថ ការវិនិច្ឆ័យរោគផ្សេងៗ។

**១.៤. ប្រភេទនៃសំរាម**

សំរាមមានច្រើនប្រភេទបើឱ្យយើងរៀបរាប់មានដូចជា ក្រដាស ផ្លាស្ទិច បន្លែផ្លែឈើសល់ស្លឹកឈើ មែកឈើ កាកសំណល់ផ្ទះបាយ កាកសំណល់ការដ្ឋានសំណង់។ ល។ ហើយមានសំរាមខ្លះអាចកែច្នៃប្រើឡើងវិញបាន និងខ្លះទៀតមិនអាចប្រើឡើងវិញបាន តែបើយោងតាមក្រុមហ៊ុនស៊ីនទ្រី និងសាលាក្រុង បានបែងចែកសំរាមជា២ប្រភេទធំៗគឺ ប្រភេទសំរាមស្ងួត និង ប្រភេទសំរាមសើម។

**១.៤.១. ប្រភេទស្ងួត**

សំរាមស្ងួត គឺជាប្រភេទសំរាមទាំងឡាយណាដែលត្រូវបានគេសម្ងួត ឬ ច្រោះទឹកចេញក្រោយពេលប្រើប្រាស់រួចដែលរួមមាន ស្បោងផ្លាស្ទិច ក្រដាស ដបទឹក កំប៉ុងភេសជ្ជៈ កែវជ័រជាដើម។ ភាគច្រើនសំរាមទាំងអស់នេះ គឺជាសំរាមដែលអាចកែច្នៃបានច្រើនប្រភេទ ដើម្បីលក់ ឬ ប្រចាំប្រើប្រាស់ឡើងវិញ ប្រភេទសំរាមស្ងួតនេះបានមកពីគ្រប់ប្រភពទាំងអស់ ដែលគេប្រើប្រាស់ថ្ងៃ។ យើងសង្កេតឃើញឈ្មួញកណ្តាលនៃសំរាមប្រភេទនេះ គឺអាជីវករអេដ៍ចាយ ដែលប្រមូលទិញ

ពីអ្នកទិញអេដ៍ចាយតូចៗតាមផ្ទះ ហើយលក់បន្តទៅឱ្យ រោងចក្រ សហគ្រាស ដែលត្រូវការដើម្បីផលិតសំភារៈប្រើប្រាស់ជាថ្មី។

### ១.៤.២. ប្រភេទសើម

សំរាមសើម គឺជាប្រភេទសំរាមទាំងឡាយណា ដែលគេមិនបានសម្ងួតក្រោយពេលប្រើប្រាស់រួចភាគច្រើនគឺជាសំរាមសរីរាង្គសំរាម ដែល ជាមានដូច បន្លែផ្លែឈើដែលស្អុយរលួយ ។ ល់ផ្ទះបាយជាដើមណកាកសំណល់អាហារ សំ ជាទូទៅប្រភេទសំរាម សូវបានប្រភេទនេះមិនត្រូវគេយកទៅកែច្នៃនោះទេ យកវាទៅដុតក្នុងឡ ដើម្បីបំលែងទៅជាថាមពលចំហេះគេច្រើន ឬស្ក័ ដើម្បីយកទៅស្រោចដំណាំកសិកម្ម ស្រែចំការយកទៅធ្វើជាជីកំប៉ុឱ្យទទួលបានផលផ្លែល្អ។

សំរាមទាំងពីរប្រភេទនេះហើយដែលក្រុមហ៊ុនស៊ីនទ្រី តែងតែប្រមូលយកជារៀងរាល់ថ្ងៃនៅតាមទីធ្លាសាធារណៈ តាមគេហដ្ឋានប្រជាពលរដ្ឋ ទីតាំងប្រកបអាជីវកម្ម និងនៅតាមអង្គការនានា បូករួមទាំងសំណល់រឹងការដ្ឋានសំណង់មួយ ចំនួនផងដែរ។

## ១.៥. ច្បាប់ និងគោលការណ៍នានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម

រដ្ឋាភិបាលប្រទេសកម្ពុជាបានសិក្សា និងរៀបចំក៏ដូចជាអនុវត្តនូវបទបញ្ញត្តិ ច្បាប់ និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង ដែលរួមមានសកម្មភាព ការផ្តួចផ្តើមផ្សព្វផ្សាយអប់រំផ្សេងៗទៅនឹងការគ្រប់គ្រងសំរាម។

### ១.៥.១. អនុក្រឹត្យ និងប្រកាសស្តីពីការគ្រប់គ្រងសំណល់រឹង

នៅខែមេសា ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើត និងប្រកាសអោយប្រើប្រាស់អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ក្នុងគោលបំណងកំណត់ការគ្រប់គ្រងសំណល់រឹង។ អនុក្រឹត្យនេះ ជាមូលដ្ឋានច្បាប់សម្រាប់កំណត់នូវការបោះចោលសំរាម ការទុកដាក់ ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការចាក់ពីលំនៅស្ថាន និងសំរាមដែលគ្រោះថ្នាក់។

ក្នុងអនុក្រឹត្យនេះ តម្រូវអោយក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ អាជ្ញាធរខេត្ត-ក្រុងបានរៀបចំផែនការគ្រប់គ្រងនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនសម្រាប់ រយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ក្នុងការអនុវត្តនូវការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់សំរាម។

បន្ថែមទៅលើអនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹង ក្រោយមកនៅក្នុងឆ្នាំ២០០៣ ក្រសួង

បរិស្ថាន និងក្រសួងមហាផ្ទៃ បានចេញប្រកាសអន្តរក្រសួងលេខ ៨០ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ មានគោលបំណងជំរុញកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរដែនដី និង សមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការគ្រប់គ្រងសំរាម នៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន សំដៅធានាអោយបាននូវកិច្ចការពារសុខភាពសាធារណៈ សោភ័ណ្ឌភាព គុណភាពបរិស្ថាន និងជីវៈចម្រុះ។ សេចក្តីប្រកាសបានកំណត់យ៉ាងច្បាស់ថា ការបោះចោល ឬ ចាក់សំរាម សំណងរឹងរាយប៉ាយតាមដងផ្លូវទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកម្សាន្ត តាមឆ្នេរច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ប្រព័ន្ធលូ ប្រព័ន្ធប្រលាយកសិកម្មត្រូវហាមឃាត់ដាច់ខាត់។

ជារួមប្រកាសអន្តរក្រសួងលេខ៨០នេះ ផ្តល់ទៅឱ្យអាជ្ញាធរដែនដីព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធនានានូវតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភ័ណភាព និងបរិស្ថានស្អាត។
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្ន ឱ្យបានសមរម្យដោយគ្មានការរំខានដល់ ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- ដាក់ស្លាកហាមចោលសំរាម និងអប់រំអោយមានការទុកដាក់សំរាម ឱ្យបានត្រឹមត្រូវ។-ល-។

ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ និងកែលម្អភាពអវិជ្ជមានទាក់ទងនឹងការគ្រប់គ្រងសំរាម នៅដើមឆ្នាំ២០១០ សាលារាជធានីភ្នំពេញ បានចាប់ផ្តើមធ្វើការផាកពិន័យ ទៅលើបុគ្គលទាំងឡាយណា ដែលបោះសំរាមក្រៅធុងនៅតាមសួនច្បារសាធារណៈ និងបានជំរុញការញែកសំរាមសើម និងស្ងួតទៅតាមទីផ្សារមួយ ចំនួននៅរាជធានីភ្នំពេញ។[9]

### ១.៥.២. អនុក្រឹត្យ និងប្រកាសស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ក្នុងនោះដែរ នៅខែសីហា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើត និងប្រកាសអោយប្រើប្រាស់អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹង ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។ អនុក្រឹត្យនេះ ជាមូលដ្ឋានច្បាប់សម្រាប់កំណត់នូវការបោះចោលសំរាម ការទុកដាក់ ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការចាក់ពីលំនៅស្ថាន និងសំរាមដែលគ្រោះ

[9] របាយការណ៍លទ្ធផលនៃការអង្កេតស្តីពិការអនុវត្តការគ្រប់គ្រងសំរាម និងសំណល់រឹងនៅរដ្ឋបាលក្រុង ស្រុក (ខែកញ្ញា ២០១៥),៨

ថ្នាក់ ព្រមទាំងហាមឃាត់នូវការបោះចោល ឬ ចាក់សំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកំម្សាន្ត តាមឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ប្រព័ន្ធលូ។

ជារួម អនុក្រឹត្យលេខ១១៣នេះ មានគោលបំណងដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា ដែលធ្វើការក្នុងផ្នែកគ្រប់គ្រងសំរាម។
- ប្រគល់ភារកិច្ចក្នុងការគ្រប់គ្រងសំរាម ទៅឱ្យរដ្ឋបាលក្រុង ស្រុក។
- កំណត់រកវិធានការចាំបាច់នានា សំដៅលើកកំពស់ប្រសិទ្ធភាព និងសុវត្ថិភាពការងារគ្រប់គ្រងសំរាម។
- លើកកំពស់ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍនិងការអនុវត្តការងារគ្រប់គ្រងសំរាមនៅតាមមូលដ្ឋាន។[10]

ជាមួយគ្នានេះ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃបានចេញនូវសារាចរអន្តរក្រសួងលេខ១០៧០ សជណ.ប.ស្ថ ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ ប្រកាសអន្តរក្រសួងនេះ មានគោលដៅប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងពីរដ្ឋបាលរាជធានី ទៅរដ្ឋបាលខណ្ឌដែលជារបត់នៃការគ្រប់គ្រងថ្មីមួយស្របទៅតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

បន្ថែមពីលើអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រង់សំរាម សំណល់រឹងទីប្រជុំជន នៅខែមករា ឆ្នាំ២០១៩ រដ្ឋបាលរាជធានីភ្នំពេញ (សាលាក្រុង) បានចេញនូវសេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញដើម្បីធ្វើអោយមានការសហការគ្នារវាងប្រជាពលរដ្ឋ ជាមួយនិងក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង (ក្រុមហ៊ុនស៊ីនទ្រី) ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ត្រូវចូលរួមធ្វើយ៉ាងណាអោយការគ្រប់គ្រងសំរាមមានប្រសិទ្ធភាពដោយបញ្ជាក់ពី របៀបរៀបចំក្នុងការចោលសំរាមរបស់ប្រជាពលរដ្ឋ និងតួនាទីរបស់ក្រុមហ៊ុនដែលផ្តល់សេវា។

ហើយថ្មីៗនេះ នៅខែមិថុនា ឆ្នាំ ២០១៩ ដោយសារសង្កេតឃើញថា មានប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មមួយចំនួនបានបញ្ចេញសំរាម សំណល់រឹងរបស់ខ្លួនមិនបានត្រឹមត្រូវតាមម៉ោង ពេលវេលាកំណត់ ធ្វើឱ្យមានសំរាមសេសសល់រាយប៉ាយតាមផ្លូវទីសាធារណៈ និងដីឡូត៍ទំនេរ ដែលធ្វើ

[10] របាយការណ៍លទ្ធផលនៃការអង្កេតស្តីពីការអនុវត្តការគ្រប់គ្រងសំរាម និងសំណល់រឹងនៅរដ្ឋបាលក្រុង ស្រុក (ខែកញ្ញា ២០១៥), ៩

ឱ្យប៉ះពាល់ដល់បរិស្ថាន សុខភាពប្រជាពលរដ្ឋ និងបាត់បង់សោភ័ណភាពរាជធានីភ្នំពេញ។ ហើយមានប្រជាពលរដ្ឋមួយចំនួនទៀត មិនបានវេចខ្ចប់ និងទុកដាក់សំរាម សំណល់រឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដោយបានដាក់សំរាម សំណល់រឹង ឡាយលំក្នុងស្បោងតែមួយមានដូចជា អំបែងកែវ អំបែងដប កញ្ចក់បាក់បែក ម្ជុរចាក់ថ្នាំ និងវត្ថុបង្កគ្រោះថ្នាក់ផ្សេងទៀត ជាមួយសំណល់ផ្ទះបាយ បង្កឱ្យមានគ្រោះថ្នាក់ របួសមុតដៃកម្មករប្រមូលសំរាមនៅពេលបំពេញការងារ រដ្ឋបាលរាជធានីភ្នំពេញបានចេញនូវសេចក្តីណែនាំស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម។

ដែលសេចក្តីណែនាំនោះមានគោលបំណងដូចខាងក្រោមៈ

- ប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មទាំងអស់ ត្រូវបញ្ចេញសំរាមរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមពេលម៉ោងដែលអាជ្ញាធរបានកំណត់។
- ប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មទាំងអស់ ត្រូវវេចខ្ចប់ និងទុកដាក់សំរាម សំណល់រឹង ដែលអាចបង្កគ្រោះថ្នាក់ដូចជា អំបែងកែវ អំបែងដប កញ្ចក់ ម្ជុរ និងវត្ថុបង្កគ្រោះថ្នាក់ផ្សេងទៀតចូលទៅក្នុងថង់ពណ៌ក្រហម ឬ ធ្វើសញ្ញាសំគាល់ដើម្បីបញ្ជាក់ដល់កម្មករប្រមូលសំរាមឱ្យមានការប្រុងប្រយ័ត្ន។

ប្រសិនបើក្នុងករណីប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្ម ដែលមិនអនុវត្តតាមសេចក្តីណែនាំនេះនឹងត្រូវទទួលការផាកពិន័យតាមអនុក្រឹត្យ លេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងព្រមទាំងការប្រឈមនឹងការបិទអាជីវកម្មនិងវិធានការផ្សេងៗទៀត។[11]

[11] សេចក្តីណែនាំ ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវ តាមកម្មវិធីសម្អាត ប្រមូលនិងដឹកជញ្ជូនសំរាម,លេខ ០០៩/១៩ សណន.ស, ខែមិថុនា ឆ្នាំ២០១៩

# ជំពូកទី ២
# ស្ថាប័នផ្សេងៗពាក់ព័ន្ធ
# នៅនឹងការគ្រប់គ្រងសំរាម

# ជំពូកទី ២ ស្ថាប័នផ្សេងៗពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម

## ២.១ . ស្ថាប័នរដ្ឋដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្ត

### ២.១.១. ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រទេសកម្ពុជាប្រគល់បេសកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិអោយសមស្របទៅនឹងនិរន្តរភាព និងការរស់នៅប្រកបដោយចីរភាពសំរាប់ជាឧត្តមប្រយោជន៍យូរអង្វែង របស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់។[12] ចំពោះការងារទាក់ទងនឹងការគ្រប់គ្រងសំរាមនេះ ក្រសួងមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- ក្រសួងបរិស្ថានមានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹង។
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬ សាធារណៈ ក្នុងការគៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង។[13]

### ២.១.២. ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ ត្រូវបានរាជរដ្ឋាភិបាលប្រទេសកម្ពុជា ប្រគល់បេសកម្មឱ្យដឹកនាំក្នុងការអនុវត្ត និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពិសេសគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ។ [14] ចំពោះការងារទាក់ទងនឹងការគ្រប់គ្រងសំរាម ក្រសួងមហាផ្ទៃត្រូវធ្វើការសហការ ព្រមទាំងធ្វើការសម្របសម្រួលជាមួយនិងក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សា និង

[12] អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន,លេខ ១៣៥ អនក្រ.បក,ខែកក្កដា២០១៦,មាត្រា២

[13] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, មាត្រា ៥

[14] អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ, លេខ២៦៤ អនក្រ.បក,តុលា ២០១៤,មាត្រា២

សម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម។[15]

ចំពោះការគ្រប់គ្រងសំរាម ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចសហប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ [16]

❖ ក្រសួងមហាផ្ទៃមានភារកិច្ចដូចជា៖

- គាំទ្រ និងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សម្របសម្រួល និងគៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់សមត្ថភាពនៃការគ្រប់គ្រងសំរាម សំណល់រឹង។
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹង ។

**២.១.៣. មន្ទីរបរិស្ថាន**

មន្ទីរបរិស្ថានរាជធានី មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី លើការងារគ្រប់គ្រងសំរាម សំណល់រឹង ។

❖ មន្ទីរបរិស្ថានមានភារកិច្ចដូចជា៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម ។
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់ថ្នាក់ក្រោមជាតិ។
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើរ ឬ គម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើការសេវាគ្រប់គ្រង និងការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

[15] សារាចរអន្តរក្រសួងស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១០៧០ សជណ.បស្ត , ១២ វិច្ឆិការ ២០១៥

[16] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក ,ខែសីហា ឆ្នាំ២០១៥,មាត្រា ៦

- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹង និងរៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម។[17]

### ២.១.៤. រដ្ឋបាលរាជធានី

រដ្ឋបាលរាជធានី មានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

❖ រដ្ឋបាលរាជធានី មានភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិការប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ជាដីកា ឬ លិខិតបទដ្ឋានគតិយុត្តនានា។
- បង្កើតការគ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកសំរាម សំណល់រឹង ដែលបានរៀបចំនៅក្នុងមូលដ្ឋាន។
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹង ប្រកបដោយសុវត្ថិភាពបរិស្ថាន និងអំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹង។[18]
- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្ម ទៅឱ្យរដ្ឋបាលខណ្ឌ ឬ សង្កាត់នូវមុខងារគ្រប់គ្រងសំរាមដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារ។
- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យា ដោយពិនិត្យលទ្ធភាពក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលខណ្ឌឱ្យស្របទៅនឹងតម្រូវការជាក់ស្តែង។

---

[17] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥,មាត្រា ៨

[18] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥,មាត្រា ៩

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណាត់កន្លែងសមស្រមសម្រាប់ស្តុកសំរាមបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។
- ធ្វើការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាមដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសំរាប់រៀបចំទីលានដាក់សំរាម ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមរវាងរាជធានី និងខេត្តដែលមានព្រំប្រទល់ជាប់គ្នា។[19]

រដ្ឋបាលរាជធានី អាចស្នើសុំបង្កើតអង្គភាព ឬ ការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមានដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។

### ២.១.៥. រដ្ឋបាលខណ្ឌ និង រដ្ឋបាលសង្កាត់

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែក ឬ ទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទៅឱ្យរដ្ឋបាលខណ្ឌ ឬ សង្កាត់។

#### ❖ រដ្ឋបាលខណ្ឌ

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញមុខងារជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹង និងមានភារកិច្ចដូចខាងក្រោមៈ

- ចាត់ចែង អនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹង។
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានា។
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[20]

#### ❖ រដ្ឋបាលសង្កាត់

រដ្ឋបាលសង្កាត់ ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើការសេវាសំរាម សំណល់រឹងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចជាៈ

- ចាត់ចែងអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹង តាមការធ្វើប្រតិភូកម្ម។

[19] សារាចរអន្តរក្រសួងស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១០៧០ សជណ.បស្ត , ១២ វិច្ឆិការ ២០១៥

[20] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, មាត្រា ១២

- ចូលរួម អប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និង ដឹកជញ្ជូន និងសេវាទុកដាក់សំរាម សំណល់រឹងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់ សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង សំរាម សំណល់រឹង។[21]

## ២.២. ស្ថាប័នឯកជន (ក្រុមហ៊ុនស៊ីនទ្រី)

### ២.២.១. រចនាសម្ព័ន្ធដឹកនាំរបស់ក្រុមហ៊ុន

ក្រុមហ៊ុនស៊ីនទ្រី ជាក្រុមហ៊ុនដែលបានទទួលការវិនិយោគលើសេវាកម្ម ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងពីសាលារាជធានីភ្នំពេញ ចាប់ពីខែសីហា ឆ្នាំ២០០២មកម្លេះ។ ក្រុមហ៊ុនមានទីស្នាក់ការនៅផ្ទះលេខ៨៤២D មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមាន លោកឧកញ៉ា **សេង សារី** ជាប្រធាន។ ហើយក្រុមហ៊ុន មានការិយាល័យចំនួន៦ការិយាល័យ រួមមានការិយាល័យរដ្ឋបាល និងធនធានមនុស្ស ការិយាល័យហិរញ្ញវត្ថុ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យអតិថិជន ការិយាល័យសម្អាតក្រុង ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់។[22]

បន្ថែមពីនេះទៅទៀត ការគ្រប់គ្រងផ្សេងៗទៀតរបស់ក្រុមហ៊ុនស៊ីនទ្រី មានរចនាសម្ព័ន លំអិតសូមមើលនៅក្នុង (ឧបសម្ព័ន្ធទី ៦) ។

### ២.២.២. ផ្នែកទទួលបន្ទុកផ្សេងៗរបស់ក្រុមហ៊ុន

ក្រុមហ៊ុនស៊ីនទ្រី មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើការផ្តល់នូវសេវាកម្មប្រមូល និងដឹកជញ្ជូនសំរាម ២៤ម៉ោងក្នុងរាជធានីភ្នំពេញ។
- ចូលរួមអប់រំ ផ្សព្វផ្សាយ ចាត់វិធានការទប់ស្កាត់ការចោលសំរាមនៅទីសាធារណៈ។
- ធ្វើប្រតិបត្តិការបោសសម្អាតតាមដងមហាវិថី និងវិថីនានា និងការប្រមូលសំរាមនៅតាមទីផ្សារ ផ្ទះភោជនីយដ្ឋាន និងតំបន់អាជីវកម្មនានា។

[21] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក ,ខែសីហា ឆ្នាំ២០១៥, មាត្រា ១៣

[22] ក្រុមហ៊ុនស៊ីនទ្រី,របាយការបូកសរុបលទ្ធផលការងារឆ្នាំ ២០១៨ និងទិសដៅការងារឆ្នាំ២០១៩

- ផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ និងអាជីវករ សេវាករ អោយញែក វេចខ្ចប់ និងទុកដាក់សំរាមអោយបានត្រឹមត្រូវតាមម៉ោងពេល និងទីកន្លែងកំណត់តាមរូបភាពឃោសនា ឬ ចែកលិខិតប័ណ្ណអប់រំតាមលំនៅដ្ឋាន និងនៅតាមទីតាំងមួយចំនួនដូចជា ទីផ្សារ ចំណតរថយន្ត កន្លែងកំសាន្ត សួនច្បារ និងតាមភោជនីយដ្ឋាន។
- រៀបចំធុងដាក់សំរាមនៅតាមទីសាធារណៈ សួនច្បារ និងតាមផ្លូវសាធារណៈសំខាន់ៗទៅតាមប្រភេទនៃសំរាម និងសំណល់រឹងនីមួយៗ។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធធ្វើការផ្សព្វផ្សាយ និងធ្វើកម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹងដល់អាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ប្រជាពលរដ្ឋគ្រប់លំនៅឋាន និងគ្រប់ម្ចាស់ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈនិងឯកជននានានៅក្នុងរាជធានីភ្នំពេញឱ្យបានដឹង ដើម្បីងាយស្រួលបញ្ចេញសំណល់អោយបានស្របគ្នានឹងម៉ោងដឹកជញ្ជូន។[23]
- ធ្វើការផាកពិន័យចំពោះអ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងខុសពីការណែនាំរបស់អាជ្ញាធរ មូលដ្ឋានដោយអនុវត្តន៍តាមខ្លឹមសារ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៧។[24]

[23]រដ្ឋបាលរាជធានីភ្នំពេញ, សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ,លេខ ០០២/១៩ សណន.ស

[24] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, ជំពូក៧

# ជំពូកទី ៣
# ដំណើការនៃការគ្រប់គ្រង
# សំរាម( ក្រុមហ៊ុនស៊ីនទ្រី )

## ជំពូកទី ៣ ដំណើរការនៃការគ្រប់គ្រងសំរាម(ក្រុមហ៊ុនស៊ីនទ្រី)

សំរាមត្រូវបានប្រមូល ក៏ដូចជាដឹកជញ្ជូនជារៀងរាល់ថ្ងៃនៅក្នុងរាជធានីភ្នំពេញទៅតាមកាលវិភាគនៃការកំណត់តំបន់សំរាប់ការប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី។ ក្រុមហ៊ុនស៊ីនទ្រី បានធ្វើកិច្ចព្រមព្រៀង ស្តីពីការសម្អាត ប្រមូល និងការដឹកជញ្ជូនសំរាម ជាមួយនិងរដ្ឋបាលនីមួយៗទាំង ១២ខណ្ឌនៅក្នុងរាជធានីភ្នំពេញ។ ដែលកិច្ចព្រមព្រៀងនោះបានកំណត់ពីទីកន្លែង និងពេលវេលាក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី។[25] កិច្ចព្រមព្រៀងនោះធ្វើឡើងដូចខាងក្រោម៖

| ថ្ងៃ ខែ ឆ្នាំ | តំណាងក្រុមហ៊ុនស៊ីនទ្រី និងតំណាងខណ្ឌនីមួយៗ |
|---|---|
| ២៤ កម្ភៈ ២០១៦ | សាលាខណ្ឌ៧មករា ដែលមានអាសយដ្ឋាននៅ អគារលេខ៥៤ ផ្លូវលេខ១៦៩ រាជធានីភ្នំពេញតំណាងដោយលោក លឹម សុភា អភិបាលនៃគណៈអភិបាលខណ្ឌ៧មករា។ http://www.cintri.com.kh/PDF/7MK3%20%28Khan%20checked%20already%29.pdf |
| ២១ ធ្នូរ ២០១៦ | សាលាខណ្ឌច្បារ អំពៅ ដែលមានអាសយដ្ឋាន ស្ថិតនៅលើផ្លូវលេខ៣៦១ ភូមិម៉ាក់ក្លឿរ សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ តំណាងដោយលោកអ៊ាង ស៊ីផាន អភិបាលនៃគណៈអភិបាលខណ្ឌច្បារអំពៅ។ http://www.cintri.com.kh/PDF/Chbar%20Ompov.pdf |
| ២៤ កុម្ភៈ ២០១៦ | សាលាខណ្ឌចំការមន ដែលមានអាសយដ្ឋាន ស្ថិតនៅអាគារលេខ១៦៨ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ តំណាងដោយលោកព្រុំ សំខាន់ អភិបាលនៃគណៈអភិបាលខណ្ឌចំការមន។ http://www.cintri.com.kh/PDF/Chbar%20Ompov.pdf |
| ២១ ធ្នូរ | សាលាខណ្ឌដង្កោ ដែលមានអាសយដ្ឋានស្ថិតនៅបណ្តោយផ្លូវលេខ២១៧ ភូមិថ្មី សង្កាត់ដង្កោ រាជធានីភ្នំពេញ តំណាងដោយលោកនុត ពុធដារ៉ា អភិបាលនៃគណៈអភិបាលខណ្ឌដង្កោ។ http://www.cintri.com.kh/PDF/Dangkor.pdf |

[25] http://www.cintri.com.kh/view.aspx?LID=KH&mID=H11&fbclid=IwAR24-(ចូលទស្សនាចុងក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩)
ekVU9UjUY5NPXTetF0fbWWXk1Cmn9A3d9KF_19jbZdMtw67TS1kW1M (ចូលទស្សនាចុងក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩)

| | |
|---|---|
| ២០១៦ | |
| ២៤ កុម្ភ: ២០១៦ | សាលាខណ្ឌភ្នំពេញ ដែលមានអាសយដ្ឋាន ស្ថិតនៅអាគារលេខ១១ ផ្លូវ៩០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ តំណាងដោយលោកគួច ចំរើន អភិបាលនៃគណ:អភិបាលខណ្ឌដូនពេញ។ http://www.cintri.com.kh/PDF/DP%20(Khan%20checked%20already).pdf |
| ២១ ធ្នូ ២០១៦ | សាលាខណ្ឌព្រែកព្នៅ ដែលមានអាសយដ្ឋាន ស្ថិននៅអាគារលេខ៤២ ផ្លូវទំនប់កប់ស្រូវ ភូមិផ្សារខាងលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ តំណាងដោយ សុខ សម្បត្តិ អភិបាលនៃគណ:អភិបាលខណ្ឌព្រែកព្នៅ។ http://www.cintri.com.kh/PDF/Prek%20Pnov.pdf |
| ១៤ កក្កដា ២០១៦ | សាលាខណ្ឌឫស្សីកែវ ដែលមានអាសយដ្ឋាន ស្ថិតនៅតាមផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ តំណាសងដោយលោក ជា ពិសី អភិបាលនៃគណ:អភិបាលខណ្ឌឫស្សីកែវ។ http://www.cintri.com.kh/PDF/Russey%20Keo.pdf |
| ១៤ កក្កដា ២០១៦ | សាលាខណ្ឌសែនសុខ ដែលមានអាសយដ្ឋានស្ថិតនៅដីឡូត៍លេខ២៦២ ផ្លូវហាណូយ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ តំណាងដោយលោកប៉ឹល កុសល អភិបាលនៃគណ:អភិបាលខណ្ឌសែន សុខ។ http://www.cintri.com.kh/PDF/Sen%20Sokh.pdf |
| ២៤ កុម្ភ: ២០១៦ | សាលាខណ្ឌទួលគោក ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ១៧៥ ផ្លូវលេខ១៨២ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងដោយលោកឯក យុនដឿន អភិបាលនៃគណ:អភិបាលខណ្ឌទួលគោក។ http://www.cintri.com.kh/PDF/TK3%20(Khan%20checked%20already).pdf |
| ១៤ កក្កដា ២០១៦ | សាលាខណ្ឌពោធិ៍សែនជ័យ ដែលមានអាសយដ្ឋាន ស្ថិតនៅតាមផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់កាកាប រាជធានីភ្នំពេញ តំណាងដោយលោកហៃម ដារិទ្ធិ អភិបាលនៃគណ:អភិបាលខណ្ឌពោធិ៍សែនជ័យ។ http://www.cintri.com.kh/PDF/Pur%20Senchey.pdf |
| ២១ | សាលាខណ្ឌជ្រោយចង្វារ ដែលមានអាសយដ្ឋាន ស្ថិតនៅតាមផ្លូវជាតិលេខ៦ ភូមិគៀនឃ្លាំង សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ តំណាងដោយ |

| | |
|---|---|
| ធ្នូ ២០១៦ | លោកឃ្លាំង ហួត អភិបាលនៃគណៈអភិបាលខណ្ឌជ្រោយចង្វារ។ http://www.cintri.com.kh/PDF/Chrouy%20Changva.pdf |
| ១៤ កក្កដា ២០១៦ | សាលាខណ្ឌមានជ័យ ដែលមានអាសយដ្ឋាន ស្ថិននៅអាគារថ្មី ចូលតាមផ្លូវ៣០ ម៉ែត្រ ផ្លូវព្រែកតាឡុង១ សង្កាត់ចាក់អង្រែក្រោម រាជធានីភ្នំពេញ តំណាងដោយ លោកពេជ្រ កែវមុនី អភិបាលនៃគណៈអភិបាលខណ្ឌមានជ័យ។ http://www.cintri.com.kh/PDF/Meanchey.pdf |

## ៣.១. ការប្រមូលសំរាម

សំរាមត្រូវបានប្រមូល ក៏ដូចជាដឹកជញ្ជូនជារៀងរាល់ថ្ងៃនៅក្នុងរាជធានីភ្នំពេញទៅតាមកាលវិភាគនៃការកំណត់តំបន់នៃការប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី។ ហើយសំរាមទាំងនោះត្រូវប្រមូល និងដឹកជញ្ជូនយកទៅចាក់នៅទីលានចាក់សំរាម។ ចំពោះទីលានចាក់សំរាមនៅរាជធានីភ្នំពេញ ស្ថិតនៅខណ្ឌដង្កោ រាជធានីភ្នំពេញ មានទំហំ ៣១,៤ ហិកតា ចែកចេញជា ៤ រណ្តៅ គឺរណ្តៅ A, B, C និងរណ្តៅ D។ មកដល់ត្រឹមឆ្នាំ២០១៨ រណ្តៅ A និង B បានចាក់ពេញ និងបានគ្របដីត្រឹមត្រូវ។ បច្ចុប្បន្ន សំរាម កំពុងបន្តចាក់ចូលក្នុងរណ្តៅ C និង D។[26]

ទោះបីជាយ៉ាងណាក៏ដោយយើងសង្កេតឃើញថា សំរាមមានការកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ បរិមាណសំរាមដែលបានយកទៅចាក់នៅទីលានចាក់សំរាមជាមធ្យម មានចំនួន៧៧៦៨៣តោន ដែលមានកំណើនមធ្យមជាស្មើនឹង ១៨%។ សរុបក្នុងឆ្នាំ២០១៨ សំរាមដែលត្រូវបានប្រមូល និងដឹកជញ្ជូនទៅចាក់នៅទីលានចាក់សំរាមមាន ចំនួន ៨៥៤,៥១០តោន។[27]

### ៣.១.១. បុគ្គលិក

ក្រុមហ៊ុនស៊ីនទ្រី មានរចនាសម្ព័ន្ធគ្រប់គ្រង ចំនួន៦ការិយាល័យ ដែលរួមមានការិយាល័យរដ្ឋបាល និងធនធានមនុស្ស ការិយាល័យហិរញ្ញវត្ថុ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យអតិថិជន ការិយាល័យសម្អាតក្រុង ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់។[28] ក្នុងនោះផងដែរ ក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនមានបុគ្គលិកសរុបចំនួន ២៤០៤នាក់ ដែលចែកចេញជា កម្មករប្រមូលសំរាមចំនួន១៧០០នាក់ អ្នកបើកបររថយន្តចំនួន ៤០០នាក់ បុគ្គលិកអតិថិជនចំនួន ១០០នាក់ អ្នកគ្រប់គ្រងកម្មករ និងរថយន្តដឹកសំរាមចំនួន៥០ និងបុគ្គលិកនៅផ្នែកផ្សេងៗទៀតចំនួន ១៥៤នាក់។ បើធៀបនឹងឆ្នាំ

[26] http://kleykley.sabay.com.kh/article/1053188 (ចូលទស្សនាចុងក្រោយ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩)

[27] ក្រុមហ៊ុនស៊ីនទ្រី, របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០១៨ និងទិសដៅការងារឆ្នាំ២០១៩

[28] ក្រុមហ៊ុនស៊ីនទ្រី, របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០១៨ និងទិសដៅការងារឆ្នាំ២០១៩

២០១៧ បុគ្គលិកមានការកើនឡើងចំនួន ១១៤នាក់ និងកើនឡើងចំនួន១៦៧នាក់បើធៀបនឹងឆ្នាំ ២០១៦។[29]

### ៣.១.២. សម្ភារៈ

ដើម្បីបង្កើនប្រសិទ្ធភាព និងសេវាកម្មអោយកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ទាក់ទងនឹងការបោសសម្អាតតាមដងមហាវិថី វិថី និងការប្រមូលសំរាមនៅតាមទីផ្សារ ផ្ទះ ភោជនីយដ្ឋាន និងតំបន់អាជីវកម្មនានា។[30]ក្នុងឆ្នាំ២០១៨នេះ ក្រុមហ៊ុនត្រូវប្រើប្រាស់សម្ភារៈដូចជា រថយន្តដឹកសំរាមគ្រប់ខ្នាត (compactor) ចំនួន៤៤៥គ្រឿង ហ្សាស័រ (គ្រឿងចក្រសំរាប់ចូកសំរាមដេប៉ូធំៗ) ចំនួន ១៧ គ្រឿង រថយន្តបោសចំនួន ១៧គ្រឿង រទេះដឹកសំរាមចំនួន ២៨៤ ។ ហើយសំរាមធុងដាក់សំរាមវិញមានដូចជាធុងដាំស្ទ័រ ធុងស្មាច់ចាស់ ធុងសំរាមថ្មីដាក់តាមសួនច្បារ និងធុងសំរាមចំណុះ ១៤០លីត្រសំរាប់កម្មករបោស។ ក្នុងនោះផងដែរ សំរាប់ធុងដាំស្ទ័រមានចំនួន៧៣ និងធុងសំរាមចំណុះ ១៤០ លីត្រសំរាប់កម្មករបោសមានចំនួន ៣៤៩ធុង។

បើធៀបទៅនឹងឆ្នាំមុនៗ ចំនួនរថយន្តមានការកើនឡើងចំនួន ៨៦គ្រឿង បើធៀបនឹងឆ្នាំ ២០១៧ និងកើនឡើងចំនួន ១២៨គ្រឿង ធៀបនឹងឆ្នាំ២០១៦។ បន្ថែមពីនេះទៀត រទេះដឹកសំរាមកើនចំនួន ២២គ្រឿង ធៀបនឹងឆ្នាំ២០១៧ ។ ទាក់ទងនឹងធុងដាំស្ទ័រ មានការថយចុះចំនួន ០១ ដោយសារក្នុងឆ្នាំ២០១៧ ទីតាំងមួយចំនួនត្រូវបានដកធុងដាំស្ទ័រចេញឈប់អោយមាន។ ធុងស្មាត់ចាស់ ធុងសំរាមថ្មីដាក់តាមសួនច្បារថយចុះ៤០ធុងដោយសារសេរីនេះលែងមានការប្រើបន្តទៀត និងធុងអ្នកបោសថយចុះចំនួន ១៣ធុង។

## ៣.២. ការគិតថ្លៃសេវា

ការប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម ត្រូវមានការទទួលយកសេវាពីក្រុមហ៊ុន (ក្រុមហ៊ុនស៊ីនទ្រី) ដែលទទួលបានអាជ្ញាប័ណ្ណប្រមូល និងដឹកជញ្ជូនសំណល់ទាំងនេះ។ ហើយម្ចាស់ទីតាំងទាំងអស់ត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូននិងសេវាទុកដាក់សំណល់ទាំងនោះ ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ និងក្រសួងស្ថាប័នពាក់ព័ន្ធ។ លើសពីនេះ ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬ ប្រព្រឹត្តល្មើសទៅនឹងការហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣ ស្តីពីការគ្រប់គ្រងសំណល់រឹងទីប្រជុំជនត្រូវពិន័យតាមច្បាប់ជាធរមាន។

### ៣.២.១. សេវាលើការប្រមូល សម្អាត និងដឹកជញ្ជូន

[29] កិច្ចសំភាសតំណាង**ក្រុមហ៊ុន ស៊ីនទ្រី** លោក**សឿន សារ៉េន** «ជំនួយការប្រធានការិយាល័យសម្អាតក្រុង»

[30] ក្រុមហ៊ុនស៊ីនទ្រី,របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០១៨ និងទិសដៅការងារឆ្នាំ២០១៩

ភ្ជាប់ទៅនឹងប្រកាសអន្តរក្រសួងលេខ១៩៥ ប្រក.បស្ក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់តម្លៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានីភ្នំពេញបានចេញសេចក្តីជូនដំណឹងស្តីពីកម្រៃសេវាថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញដល់ប្រជាពលរដ្ឋដែលជាម្ចាស់លំនៅឋាន ក្រុមហ៊ុន រោងចក្រ សហគ្រាស និងទីតាំងប្រកបអាជីវកម្ម-សេវាកម្មគ្រប់ប្រភេទ ដោយបញ្ជាក់ពីហេតុដោយមានការកើនឡើងនូវកំណើនផ្ទៃដីកំណើនសេដ្ឋកិច្ច និងកំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ហើយបរិមាណសំរាមក៏មានការកើនឡើងផងដែរនោះ។[31] ទន្ទឹមនិងនេះ ដើម្បីពង្រឹកបន្ថែមនូវការផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់អោយបានល្អ សំដៅធ្វើឱ្យរាជធានីភ្នំពេញមានសោភ័ណភាព អនាម័យ និងបរិស្ថានស្អាតរដ្ឋបាលរាជធានីភ្នំពេញបានដាក់ចេញនូវតារាងកំណត់តម្លៃសេវាប្រមូលសំរាមថ្មីនេះ ដែលបានរៀបរាប់លម្អិតនូវតម្លៃសម្រាប់អាគារគ្រប់ប្រភេទ រាប់ចាប់តាំងពីលំនៅឋានសម្រាប់រស់នៅ ក្រុមហ៊ុន សហគ្រាស រោងចក្រ និងទីតាំងប្រកបអាជីវកម្ម សេវាកម្មគ្រប់ប្រភេទទាំងអស់ក្នុងរាជធានីភ្នំពេញ។[32] យោងតាមតារាងកំណត់តម្លៃថ្មីដែលបានផ្សព្វផ្សាយបញ្ជាក់ថា សម្រាប់លំនៅឋានរស់នៅធម្មតាគឺផ្ទះល្វែងជាន់ផ្ទាល់ដី មានតម្លៃ ១០៦០០ រៀល ផ្ទះល្វែងជាន់ទី ១ ឡើងទៅមានតម្លៃ ៧៦០០ រៀល ផ្ទះដីឡូត៍ធម្មតា ១៩១០០ រៀល ផ្ទះភូមិគ្រឹះផ្ទៃដីតូចជាង ៣០០ ម៉ែត្រការ៉េ មានតម្លៃ ៣១០០០ រៀល ចំណែកភូមិគ្រឹះមានផ្ទៃពី ៣០០ ដល់ ៦០០ ម៉ែត្រការ៉េ មានតម្លៃ ៥០៥០០ រៀល។ [33]ហើយតម្លៃលំអិតផ្សេងទៀតទាក់ទងទៅនឹងក្រុមហ៊ុន រោងចក្រ និងទីតាំងប្រកបអាជីវកម្ម សេវាកម្មគ្រប់ប្រភេទ សំរាប់ការបង់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងនេះផងដែរសូមមើលនៅក្នុងតាមតារាងថ្មី **<<តារាងកំណត់តម្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ>>** (សូមមើលនៅក្នុងឧបសម្ព័នទី៤)។

### ៣.២.២. ការផាកពិន័យ

នៅក្នុងអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងសារាចរណែនាំរបស់សាលារាជធានីភ្នំពេញស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញបានកំណត់យ៉ាងច្បាស់លាស់ពីតម្លៃផាកពិន័យផ្សេងៗ ទាក់ទងទៅនឹងការមិនអនុវត្តន៍តាម

[31] ប្រកាសអន្តរក្រសួងលេខ១៩៥ ស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

[32] h//www.postkhmer.com/ព័ត៌មានជាតិ/តម្លៃសេវាប្រមូលសំរាមនឹងកើនជិត-៣-ដង-ចាប់ពីខែមេសានេះទៅttps: (ចូលទស្សនាចុងក្រោយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩)

[33] សេចក្តីជូនដំណឹងស្តីពីកម្រៃសេវាថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅរាជធានីភ្នំពេញ, លេខ០២០/១៩ សជណ.ស, ២៦ កុម្ភៈ ២០១៩

កាកំណត់របស់អនុក្រឹត្យលេខ១១៣ និងសារាចររដ្ឋបាលរាជធានី ក្នុងការញែក ការវិចខ្ចប់ និងការចោលសំរាមគ្មានសណ្តាប់ធ្នាប់ជាដើមនិងត្រូវទទួលការផាកពិន័យជាអន្តរការណ៍។ [34]

តម្លៃសេវាផាកពិន័យមានសមាមាត្រខុសគ្នាទៅតាមទោសបញ្ញត្តិដូចខាងក្រោមៈ

១. ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬ កែច្នៃបានត្រូវទទួលការពិន័យអន្តការណ៍ជាប្រាក់ដូចខាងក្រោមៈ

- ចំនួន ១០.០០០រៀល សំរាប់លំនៅឋាន។
- ចំនួន ១០០.០០០រៀល សំរាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូរ អាប៉ាតមែន និងបុរីលំនៅឋាន។
- ចំនួន២០០.០០០រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។[35]

២. បុគ្គលដែលនាំយកកញ្ចប់ ឬ ធុងផ្ទុកសំរាម ទៅដាក់នៅតាមដងផ្លូវ ឬ ទីសាធារណៈខុសម៉ោងអនុញ្ញាតអោយធ្វើការបញ្ចេញ ដែលកំណត់ដោយសាលារាជធានីភ្នំពេញ ត្រូវទទួលពិន័យអន្តការណ៍ដូចខាងក្រោមៈ

- ចំនួន ២០.០០០រៀល សំរាប់លំនៅឋាន។
- ចំនួន ១៥០.០០០ រៀល សំរាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីទាំងសិប្បកម្ម អគារខុនដូរ អាប៉ាតឹមែន និងបុរីលំនៅឋាន។
- ចំនួន ៤០០.០០០រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។[36]

៣. បុគ្គលដែលបោះចោលសំរាម នៅទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬ ទីកន្លែងដែលរដ្ឋបាលរាជធានី បានហាមឃាត់ការចោលសំរាម ត្រូវទទួលការពិន័យជាប្រាក់ៈ

- ចំនួន ២០.០០០រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាតយកទៅដាក់ក្នុងធុងសំរាមសាធារណៈ។
- ចំនួន ៥០.០០០រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬ ទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់។
- ចំនួន ១៥០.០០០រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់។

[34] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ខែសីហា ២០១៥, ជំពូក ៧

[35] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក ,ខែសីហា ឆ្នាំ២០១៥, ៣៩

[36]អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក ,ខែសីហា ឆ្នាំ២០១៥, ៤០

- ចំនួន ៨០០.០០០រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងការដឹកចេញយកទៅទីលាន។[37]

៤. បុគ្គលដែលដុតសំរាមនៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬ ទីកន្លែងដែលរដ្ឋបាលរាជធានី បានហាមឃាត់ការចោលសំរាម ត្រូវទទួលការពិន័យជាប្រាក់៖

- ចំនួន ៥០.០០០រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំរាមយកទៅដាក់ក្នុងធុងសំរាមសាធាណៈ។
- ចំនួន ១០០.០០០រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬ ទីសាធារណៈ និងត្រូវប្រមូលសំអាត។
- ចំនួន ៨០០.០០០រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។[38]

៥. បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់ភក់ពីប្រព័ន្ធលូ ឬ អាងសុិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ខណ្ឌ ឬ ដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ត្រូវទទួលពិន័យជាអន្តការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៨០០.០០០រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ។
- ចំនួន ១.០០០.០០០រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។[39]

៦. បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬ ប្រមូលនិងដឹកជញ្ជូនសំរាម ដែលលាយឡំគ្នារវាងសំណល់រឹងឧស្សាហ៍កម្ម សំណល់វេជ្ជសាស្ត្រ ឬ សំណល់គ្រោះថ្នាក់ ត្រូវពិន័យអន្តការណ៍ជាប្រាក់ដូចជា៖

- ចំនួន ៥០០.០០០រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព។
- ចំនួន ៨០០. ០០០រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។
- ចំនួន ១.០០០.០០០រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម។[40]

សម្រាប់អ្នកដែលមិនបានបង់ប្រាក់ពិន័យទាំងនេះក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ នឹងត្រូវដំឡើងជាពីរដង បើលើសពី៦០សិបថ្ងៃ នឹងត្រូវដំឡើងបីដង។ ហើយបើផុតរយៈពេល ៩០ថ្ងៃ រដ្ឋបាលរាជធានី ខណ្ឌ នឹងរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី។ ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសំរេចផាកពិន័យអន្តការណ៍របស់មន្ត្រីមាន

[37]អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក ,ខែសីហា ឆ្នាំ២០១៥, ៨២
[38] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, ៨៣
[39] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, ៨៤
[40] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, ៨៦

សមត្ថកិច្ចរបស់រាជធានី ខណ្ឌ បុគ្គលនោះមានសិទ្ធិប្ដឹងទៅអភិបាលរាជធានី ខណ្ឌសាមី ឬ អាច ប្ដឹងទៅតុលាកាតាមនីតិវិធីជាធរមានបាន។[41]

## ៣.៣. បញ្ហាប្រឈមនិងដំណោះស្រាយ

### ៣.៣.១. បញ្ហាប្រឈម

ក្នុងពេលប្រតិបត្តិការសម្អាត ប្រមូល និងដឹកជញ្ជូន ក្រុមហ៊ុនស៊ីនទ្រី បានជួបបញ្ហាលំបាកជាច្រើនក្នុងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញឱ្យមានប្រសិទ្ធភាពដែលធ្វើអោយមានការបន្សល់នូវសំរាមនៅកន្លែងផ្សេងៗ បញ្ហាសំខាន់ៗទាំងអស់នោះរួមមាន ៖

- នៅមានប្រជាពលរដ្ឋ បញ្ចេញសំរាមខុសកម្មវិធីប្រមូល គ្មានការវេចខ្ចប់ មិនចម្រោះទឹកចេញ។
- អ្នកលក់ដូរចល័តតាមផ្លូវសាធារណៈ គ្មានការវេចខ្ចប់សំរាមរបស់ខ្លួនអោយបានត្រឹមត្រូវ និងបញ្ចេញតាមទីសាធារណៈគ្មានការកំណត់។
- រថយន្តដឹកដី ដឹកខ្សាច់ ពុំបានសំអាតកង់រថយន្តឲ្យបានស្អាតមុនធ្វើចរាចរណ៍លើដងផ្លូវជាហេតុបណ្ដាលឲ្យជាប់ដីតាមដងផ្លូវ និងខ្លះទៀតពុំមានតង់គ្រប់ដីលើរថយន្ត កត្តានេះធ្វើឲ្យជ្រុះដីរាយប៉ាយពេញផ្លូវ។
- រថយន្តដឹកខ្សាច់នៅតែបន្តជ្រុះ និងមានទឹកហៀរតាមដងផ្លូវ។
- ការដ្ឋានសាងសង់មួយចំនួនធំគ្មានការវេចខ្ចប់ទុកដាក់សម្ភារៈ សំណល់សំណង់ឲ្យបានត្រឹមត្រូវ នៅរាយប៉ាយពាសពេញផ្លូវ។ [42]

➢ **បញ្ហាលើការងារប្រមូល និងដឹកជញ្ជូន**

- ទីលានចាក់សំរាមខណ្ឌដង្កោពិបាកចូលចាក់ និងស្ទះជាញឹកញាប់ ដែលបង្កអោយការប្រមូលសំរាមមិនបានតាមកម្មវិធី និងបង្កអោយខូចគ្រឿងក្រោម បែកកង់រថយន្តយ៉ាងដំណំ។
- ពេលយប់ផ្លូវមួយចំនួនងងឹត ជាហេតុធ្វើអោយការងារប្រមូលសំរាមនៅពេលយប់ជួបផលលំបាកច្រើន។
- គ្មានទីតាំងសំរាប់ផ្ទុកធុងដាំស្ទ័រ ជាផលវិបាកក្នុងការទុកដាក់សំរាមរទេះ ដែលបានប្រមូលសំរាមបញ្ចេញខុសម៉ោង ឬ ខុសកម្មវិធីប្រមូល និងរទេះដែលអូសសំរាមចេញពីផ្លូវជឿងហែម។
- ផ្សារមួយចំនួននៅមានកន្លែងទុកដាក់សំរាម និងមិនទាន់មានធុងដាំស្ទ័រទុកដាក់សំរាម(សំរាមផ្សារ) ដែលធ្វើអោយសំរាមនៅតែបន្តចោលនៅមុខផ្សារ ឬ ផ្លូវក្បែរផ្សារ។

---

[41] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន,លេខ១១៣ អនក្រ.បក, ខែសីហា ឆ្នាំ២០១៥, ៨៨

[42] ក្រុមហ៊ុនស៊ីនទ្រី, របាយការណ៍បូកសុរប្រចាំឆ្នាំ២០១៨ ទិសដៅការងារឆ្នាំ២០១៩

- បញ្ហាចតរថយន្តគ្មានសណ្តាប់ធ្នាប់សងខាងផ្លូវ ដែលធ្វើអោយប៉ះពាល់ ដល់ការបោសសម្អាត និងការប្រមូល។
- ហេដ្ឋារចនាសម្ព័នផ្លូវមួយចំនួន នៅតាមជាយក្រុងនៅមានកំរិត ដែលបង្កបញ្ហាលំបាកដល់ផ្នែកសេវាប្រមូល និងដឹកជញ្ជូនសំរាម (តូចចង្អៀតព្រមទាំងមានខ្សែភ្លើងរញ៉េរញ៉ៃ និងមានការលិចទឹកនៅរដូវវស្សា)។
- ពេលយប់អ្នកបើកបរ (សំដៅដល់អ្នកចេញមកពីតាមខ្លឹបផ្សេងៗ) ស្រវឹងច្រើនដែលបង្កជាគ្រោះថ្នាក់ដល់កម្មករ ដែលកំពុងបម្រើការងារ។
- ធុងសំរាម និង រទេះអូសសំរាមដែលបានដាក់នៅតាមសួនច្បារ និងទីសាធារណៈត្រូវជនខិលខូចវាយបំផ្លាញនិងលួច។
- បញ្ហាអេតចាយ និងការហែកស្បោងសំរាមធ្វើអោយសំរាមរាយប៉ាយខុសសភាពដើម និងគ្មានសណ្តាប់ធ្នាប់។

➢ **បញ្ហាលើការបង់ថ្លៃសេវា**

មានអតិថិជនមួយចំនួនមិនបានបំពេញកាតព្វកិច្ចបង់ថ្លៃ សេវាបោសសម្អាត ប្រមូល និងដឹកជញ្ជូន។[43]

**៣.៣.២. ដំណោះស្រាយ**

ជាទូទៅដំណោះស្រាយគឺត្រូវមើលទៅលើវិវាទ ថាតើវិវាទនោះបង្កឡើងដោយក្រុមហ៊ុនស៊ីនទ្រី ឬ មួយក៏ប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មទូទៅដែលជាអតិថិជនរបស់ក្រុមហ៊ុន។

**ក. ដំណោះស្រាយចំពោះកំហុសដែលបង្កឡើងដោយក្រុមហ៊ុនផ្តល់សេវា**

ចំពោះកំហុសបង្កដែលឡើងដោយក្រុមហ៊ុនស៊ីនទ្រី គឺជាវិវាទលើបញ្ហាកកស្ទះខកខានការប្រមូលសំរាមរបស់ក្រុមហ៊ុន វាកើតឡើងដោយសារបញ្ហា ឡានខូច សំរាមកកស្ទះនៅទីលានចាក់សំរាមជាដើម។ ចំពោះដំណោះស្រាយ គឺក្រុមហ៊ុនបញ្ជូនឡានសំរាមនៅទិសដៅផ្សេងគ្នាដើម្បីទៅជួយរំដោះសំរាមពីកន្លែងដែលកកស្ទះឆ្លើយតបទៅនឹងសភាពការបន្ទាន់របស់អតិថិជន។

**ខ. ដំណោះស្រាយចំពោះកំហុសដែលបង្កឡើងដោយប្រជាពលរដ្ឋ - ម្ចាស់អាជីវកម្មទូទៅ**

ចំពោះកំហុសដែលបង្កឡើងដោយប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មទូទៅ គឺជាការមិនបង់ថ្លៃសេវាដឹកជញ្ជូនសំរាមជូនក្រុមហ៊ុនស៊ីនទ្រី នីតិវិធីនៃការដោះស្រាយបញ្ហាវិវាទរបស់ក្រុមហ៊ុនស៊ីនទ្រី បានបែកចែកទៅតាមដំណាក់កាលៈ

**ដំណាក់កាលទី១** ៖ ការចែកលិខិតជូនដំណឹងចំពោះការអាក់ខានបង់ថ្លៃសេវា

[43] ក្រុមហ៊ុនស៊ិនទ្រី , របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩,៧

គឺជាជំហានដំបូងដែលក្រុមហ៊ុនជូនដំណឹងដល់អតិថិជនតាមរយៈបុគ្គលិកដែលកាន់ការងារនៅតាមសង្កាត់ ក្នុងការបញ្ជូនលិខិតទៅតាមផ្ទះ តាមស្ថាប័ន ឬតាមទីតាំងអាជីវកម្មនានា ដើម្បីឱ្យម្ចាស់ភាគីទាំងអស់នោះមកដោះស្រាយបញ្ហាខកខានបង់ថ្លៃសេវានៅក្រុមហ៊ុនផ្ទាល់ក្នុងការបង់សេវាឡើងវិញដើម្បីបញ្ចប់បញ្ហា និងជាការរំលឹកដល់អតិថិជន។

**ដំណាក់កាលទី២** ៖ ការចុះទៅជួបដោះស្រាយផ្ទាល់

ក្រុមហ៊ុនបញ្ជូនបុគ្គលិកទៅជួបអតិថិជន ដើម្បីចរចារ និងពន្យល់ឱ្យប្រជាពលរដ្ឋព្រមបង់សេវាមកដល់ក្រុមហ៊ុន។

**ដំណាក់កាលទី៣** ៖ ការចែកលិខិតមេធាវីរបស់ក្រុមហ៊ុនស៊ីនទ្រី

ក្នុងករណីអតិថិជនមិនព្រមបង់តម្លៃសេវាក្រោយពីបុគ្គលិកចុះទៅជួបផ្ទាល់ទៀត ក្រុមហ៊ុននឹងជូនលិខិតមេធាវីដើម្បីអញ្ជើញមកដោះស្រាយបញ្ហាសេវានៅការិយាល័យមេធាវីរបស់ក្រុមហ៊ុនស៊ីនទ្រី។

**ដំណាក់កាលទី៤** ៖ ការប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ

ជាជំហានចុងក្រោយនៃការបញ្ចប់វិវាទ ប្រសិនបើអតិថិជននៅតែមិនព្រមបង់ថ្លៃសេវានោះ ក្រុមហ៊ុនស៊ីនទ្រី នឹងដាក់ពាក្យបណ្តឹងទៅកាន់សាលាដំបូងរាជធានីដើម្បីកោះហៅបុគ្គលដែលមិនព្រមបង់ថ្លៃសេវានោះមកដោះស្រាយនៅសាលាដំបូងតែម្តង។[44]

[44] កិច្ចសំភាសតំណាង**ក្រុមហ៊ុន ស៊ីនទ្រី** លោក**សឿន សារ៉ន** «ជំនួយការប្រធានការិយាល័យសម្អាតក្រុង»

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សានិងស្វែងយល់អំពី ដំណើរការនៃការគ្រប់គ្រងសំរាមនៅរាជធានីភ្នំពេញរួចមក យើងឃើញថានៅក្នុងឆ្នាំ២០១៩ នេះគឺមានភាពល្អប្រសើរឡើងបើធៀបនឹងឆ្នាំមុនៗ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅតែមានបញ្ហាជាច្រើនមករាំងស្ទះក្នុងដំណើការមួយនេះ ដែលជាហេតុធ្វើឱ្យដំណើការនៃការអនុវត្តមិនទទួលបានជោគជ័យ១០០% ញយ៉ាងណាមិ បញ្ហាទាំងអស់នោះមានដូចជា ប្រជាពលរដ្ឋមិនទាន់យល់អំពីរបៀបក្នុងការទុកដាក់សំរាម គ្មានការវេចខ្ចប់បានត្រឹមត្រូវនាំលនសំណង់កកើតឡើងច្រើនហួសប្រមាណ ដែការដ្ឋាឱ្យបរិមាណសំរាមកើនឡើងទ្វេដង រីទីលានចាក់សំងរាមក៏ជាបញ្ហាចោទមួយដ៏ធំដែលផ្លូវពិបាក់ចូលចាក់ និងស្ទះជាញឹកញាប់ ដែលបង្កឱ្យការប្រមូលសំរាមមិនគ្រប់ទៅតាមកម្មវិធី បូករួមទាំងបញ្ហាប្រជាពលរដ្ឋមួយចំនួនមិនបានបំពេញកាតព្វកិច្ចបង់ថ្លៃសេវាបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមផងដែរ។ ទាំងអស់នេះគឺជាបញ្ហាប្រឈមដែរក្រុមហ៊ុនស៊ីនទ្រ៉ី និងសាលារាជធានីភ្នំពេញកំពុងតែជួបប្រទះ ហើយក៏បានរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយ ដែលមានជំនួយពីគ្រប់ស្ថាប័នពាក់ព័ន្ធ ធ្វើយ៉ាងណាឱ្យដំណើរការនៃការគ្រប់គ្រងសំរាម នៅរាជធានីភ្នំពេញយើងមានភាពរីកចម្រើនប្រសើរឡើងជាលំដាប់។

បច្ចុប្បន្នសាលារាជធានីភ្នំពេញបានធ្វើបច្ចុប្បន្នភាពតារាងតម្លៃនៃការយកកម្រៃសេវាការដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនលើកទី២ ដែលអនុវត្តជាទូទៅនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ បន្ទាប់ពីតារាងតម្លៃចាស់ឆ្នាំ២០០៣។ ក្រុមហ៊ុនស៊ីនទ្រ៉ី បានបង្កើនចំនួនឡាន កម្មករ និងបុគ្គលិកជាច្រើននាក់ដើម្បីឆ្លើយតបទៅ នឹងការកើតមាននៃការកើនឡើងនូវបរិមាណសំរាម ជាក់ស្តែងយើងឃើញមានឡានដឹកសំរាមធំៗ បូករួមទាំងឡានបោសសម្អាតផងដែរ ដែលឆ្លោះបង្ហាញឱ្យឃើញថាក្រុមហ៊ុនស៊ីនទ្រ៉ី ពិតជាបានខិតខំយកចិត្ត ទុកដាក់ដើម្បីសម្អាតរាជធានីភ្នំពេញឱ្យមានសោភណ្ឌភាពល្អប្រសើរមែន។ ទន្ទឹមនឹងកិច្ចខំប្រឹងប្រែងទាំងអស់នេះមតិយោបល់មិនពេញចិត្តមួយ ចំនួននៅតែមាន ដោយគិតថាការយកតម្លៃសេវាបែបនេះមិនសមស្រប និងមិនយុត្តិធម៌ចំពោះការបង់ថ្លៃធៀបទៅនឹងការសម្អាត គ្មានតម្លាភាព និងមិនសុក្រឹត្យ ទាំងដែលប្រជាពលរដ្ឋមួយចំនួននោះមិនបានយល់ច្បាស់ថាការធ្វើបច្ចុប្បន្នភាពតារាងតម្លៃនេះគឺ មានការសិក្សាស្រាវជ្រាវយ៉ាងលម្អិតម៉ត់ចត់ និងមានការចុះហត្ថលេខាទទួលស្គាល់យ៉ាងត្រឹមត្រូវរវាងអន្តរក្រសួង ដែលរួមមាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងសាលារាជធានីភ្នំពេញផ្ទាល់ ហើយទាំងប្រជាពលរដ្ឋមួយចំនួនទៀតមិនទាំងបានបង់ថ្លៃសេវាថែមទៀតផង។ រាល់បញ្ហា

ទាំងអស់នេះ គឺជាវិវាទដែលក្រុមហ៊ុនស៊ីនទ្រីមានតួនាទីក្នុងការដោះស្រាយ ជាសេនាធិការរបស់ក្រសួងបរិស្ថាន ជាមួយនឹងអាជ្ញាធរដែនដីដើម្បីដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ។

សរុបមកប្រសិនបើចង់ឱ្យដំណើរការនៃការគ្រប់គ្រងសំរាមនៅរាជធានីភ្នំពេញ ប្រព្រឹត្តិទៅបានរលូនទាំងស្រុងលុះត្រាតែមានការចូលរួមសហការយ៉ាងល្អពីគ្រប់សំណាក់បុគ្គល ទាំងនីតិបុគ្គល និង រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ក៏ដូចជានីតិបុគ្គលឯកជន ដើម្បីឈានទៅរកដំណោះស្រាយមួយដ៏ល្អប្រសើរ ប្រៀបដូចជាចង្វាក់ផលិតកម្មឧស្សាហកម្មដូច្នោះដែរ។ បើគ្មានការសហការពីបុគ្គលណាមួយហើយ នោះនាំឱ្យដំណើរការនៃការប្រមូលសំរាមមានភាពរាំងស្ទះ វាគឺជាចន្លោះប្រហោងមួយដែលយើងគប្បីគួរតែដោះស្រាយជាចម្បង។ ភាគីដែលពាក់ព័ន្ធទាំងនោះមានបីគឺ អ្នកបង្កើតសំរាម (ប្រជាពលរដ្ឋ និងម្ចាស់អាជីវកម្មទូទៅ) អ្នកធ្វើប្រតិបត្តិការប្រមូលសំរាម (ក្រុមហ៊ុនស៊ីនទ្រី) និងស្ថាប័នពាក់ព័ន្ធនានាដើម្បីធ្វើអោយដំណើការនៃការគ្រប់គ្រប់សំរាមប្រកបទៅដោយមានប្រសិទ្ធភាព។

# អនុសាសន៍

# អនុសាសន៍

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធមានការយកចិត្តទុកដាក់ ព្រមទាំងខិតខំប្រឹងប្រែងតាក់តែងបទដ្ឋានគតិយុត្តជាច្រើន ដើម្បីដោះស្រាយ និងទប់ស្កាត់បញ្ហាសំរាមដែលកើនមានឡើងសព្វថ្ងៃនេះ។ ហើយដើម្បីដោះស្រាយ ក៏ដូចជាទប់ស្កាត់នូវបញ្ហាសំរាមនេះកើតមានឡើងយើងខ្ញុំសូមសំណូមពរឱ្យ៖

- ស្ថាប័នពាក់ព័ន្ធត្រូវពន្យល់ និងផ្សព្វផ្សាយអោយបានទូលំទូលាយទៅកាន់ប្រជាពលរដ្ឋផលវិបាកដែលកើតមានឡើងដោយបញ្ហាសំរាមនេះ។
- ប្រជាពលរដ្ឋទាំងអស់ត្រូវចូលរួមចំណែកក្នុងការកាត់បន្ថយ និងទប់ស្កាត់នូវបញ្ហាសំរាមនេះ ពីព្រោះវាមិនមែនតែជាសមត្ថកិច្ច និងទំនួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធតែម្ខាងទេ តែវាជាការទទួលខុសត្រូវរបស់ពលរដ្ឋគ្រប់រូប។ ពីព្រោះនៅពេលបញ្ហានេះកើតឡើង ប្រជាពលរដ្ឋខ្លួនឯងដែលជាអ្នកទទួលនូវផលប៉ះពាល់ជីវភាពប្រចាំថ្ងៃ។
- ក្រុមហ៊ុនផ្តល់សេវា ត្រូវមានការទទួលខុសត្រូវដោយធ្វើការផ្តល់សេវាអោយបានទៀងទាត់ និងតាមពេលវេលាដែលបានកំណត់ទៅតាមការព្រមព្រៀងជាមួយស្ថាប័នរដ្ឋ និងសមស្របទៅនឹងតម្លៃសេវាដែលទទួលបាន។ ប្រសិនបើមានការអាក់ខានក្នុងករណីណាមួយ គប្បីមានការជូនដំណឹងដល់ប្រជាពលរដ្ឋ ក៏ដូចជាម្ចាស់អាជីវកម្មទូទៅ ដើម្បីកុំឱ្យមានការទុកដាក់សំរាមចោលដោយគ្មានការប្រមូល។
- ប្រជាពលរដ្ឋទាំងអស់ រួមទាំងអ្នកផ្តល់សេវាក៏ដូចជាស្ថាប័នពាក់ព័ន្ធធ្វើការសហការគ្នា ក្នុងការបន្ថយ និងទប់ស្កាត់ការកើតមាននៅសំរាម ដោយចាប់ផ្តើមចេញពីសកម្មភាពបុគ្គលម្នាក់ដោយការមិនចោលសំរាមពាសវាលពាសការ ទប់ស្កាត់នូវការចោលសំរាមនៅទីសាធារណៈ ជាដើម។ នៅពេលដែលប្រជាជនសហការគ្នាបែបនេះ នោះប្រទេសយើងនឹងមិនមានឡើយនៅបញ្ហាសំរាម។ ដូចនេះប្រជាជនរស់នៅប្រកបដោយសេចក្តីសុខសុភមង្គលមានអនាម័យ មានសុខភាពល្អ និងសេដ្ឋកិច្ចគ្រួសារ ព្រមទាំងប្រទេសជាតិកាន់តែមានការរីកចំរើនទៅមុខ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន , លេខ១១៣ អនក្រ.បក ,២៧ សីហា ២០១៥។
- សារាចរអន្តរក្រសួង ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ១០៧០ សជណ.បស្ក ,១២ វិច្ឆិកា ២០១៥។
- ប្រកាសអន្តរក្រសួង ស្តីពីការកំណត់តម្លៃអតិបរមាស្តីពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ១៩៨ ប្រក.បស្ក ,០៦ មិថុនា ២០១៨។
- សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ,លេខ០០២/១៩ សណន.ស ,២៣ មករា ២០១៩។
- សេចក្តីណែនាំ ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវ តាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមគ្រប់ ,លេខ០០៩/១៩ សណន.ស ,១៣ មិថុនា ២០១៩។
- សេចក្តីជូនដំណឹង ស្តីពីកម្រៃសេវាថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ ០២០/១៩ សជណ.ស ,២៦ កុម្ភៈ ២០១៩

## របាយការណ៍

- ក្រុមហ៊ុនស៊ីនទ្រី , របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៨ ទិសដៅ២០១៩។
- សម្ព័នភាពក្រុមប្រឹក្សាមូលដ្ឋាន, របាយការណ៍លទ្ធផលនៃការអង្កេតស្តីពីការអនុវត្ត និង គ្រប់គ្រងសំរាម សំណល់រឹង រដ្ឋបាលក្រុង ស្រុក, ២០១៥។
- អង្គការទិន្នន័យអំពីការអភិវឌ្ឍ ,កាកសំណល់រឹង, ២៦ មិនា ២០១៦។

## គេហទំព័រ

- https://khmer.voanews.com/a/public-littering-habit-still-a-concern/3598344.html
- www.phnompenh.gov.kh
- www.moe.gov.kh/about-moe
- http://www.cintri.com.kh/PDF/7MK3%20%28Khan%20checked%20already%29.pdf
- http://www.cintri.com.kh/PDF/Chbar%20Ompov.pdf

- http://www.cintri.com.kh/PDF/Dangkor.pdf
- http://www.cintri.com.kh/view.aspx?LID=KH&mID=H11&fbclid=IwAR24-ekVU9UjUY5NPXTetF0fbWWXk1Cmn9A3d9KF_19jbZdMtw67TS1kW1M
- http://www.cintri.com.kh/PDF/DP%20(Khan%20checked%20already).pdf
- http://www.cintri.com.kh/PDF/Pur%20Senchey.pdf
- http://www.cintri.com.kh/PDF/Chrouy%20Changva.pdf

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## បញ្ជីរាយឈ្មោះក្នុងឧបសម្ព័ន្ធ

**ទំព័រ**


1. អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន , លេខ១១៣ អនក្រ.បក ,២៧ សីហា ២០១៥........................................................................................................០១
2. សារាចរអន្តរក្រសួង ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ១០៧០ សជណ.បស្ក ,១២ វិច្ឆិកា ២០១៥ ..........................................................២១
3. សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ,លេខ០០២/១៩ សណន.ស ,២៣ មករា ២០១៩.......................................................................................២៦
4. សេចក្តីជូនដំណឹង ស្តីពីកម្រៃសេវាថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ,លេខ ០២០/១៩ សជណ.ស ,២៦ កុម្ភៈ ២០១៩ .................................................................. ៣១
5. ក្រុមហ៊ុនស៊ីនទ្រី , របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៨ ទិសដៅ២០១៩....................៤០
6. រចនាសម្ព័ន្ធក្រុមហ៊ុនស៊ីនទ្រី .........................................................................................៤៨
7. រូបភាព ........................................................................................................................៤៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានកាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់កកពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជឹឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ង់ និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ង់ និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាត យកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ីបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្គាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្ដឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្ដឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្ដល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្ដល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

__កន្លែងទទួល__ ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខៈ ០៤/១៩ សណន.ស

# សេចក្ដីណែនាំ

## ស្ដីពី

## ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

សុខសន្តិភាពពេញផ្ទៃប្រទេស ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពកាន់តែធូរធារឡើងៗ ហើយសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញក៏មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃធ្វើឱ្យបរិមាណសំរាម សំណល់រឹងមានការកើនឡើងជាលំដាប់ ប៉ុន្តែការគ្រប់គ្រងសំរាមនៅមិនទាន់សមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេសនៅឡើយ ដែលតម្រូវឱ្យរដ្ឋបាលរាជធានីភ្នំពេញ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានហ្មត់ចត់។

កន្លងមក រដ្ឋបាលរាជធានីភ្នំពេញបានខិតខំប្រឹងប្រែងប្រើគ្រប់មធ្យោបាយទាំងសម្ភារ និងស្មារតី និងបានសហការជាមួយក្រុមហ៊ុន សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ប៉ុន្តែការងារនេះនៅពុំទាន់បានឆ្លើយតបតាមគោលបំណង និងសេចក្តីត្រូវការនៃភាពស្អាតរបស់ទីក្រុងនៅឡើយ ដែលតម្រូវឱ្យប្រជាពលរដ្ឋ អ្នកបង្កើតសំរាម សំណល់រឹង និងក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ព្រមទាំងអ្នកពាក់ព័ន្ធនានាចូលរួមសហការទទួលខុសត្រូវអនុវត្តឱ្យបានព្រមៗគ្នា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដូច្នេះ ដើម្បីឱ្យរាជធានីភ្នំពេញ មានសោភ័ណភាព សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថានស្អាតជានិច្ចក្លាយជាទីក្រុងបៃតង ដែលជាទីកន្លែងផ្តល់នូវសុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ និងយោងតាមច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" រដ្ឋបាលរាជធានីភ្នំពេញ សូមដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

១. ចំពោះម្ចាស់លំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ភោជនីយដ្ឋាន ទីផ្សារ ទីកន្លែងកំសាន្ត ម្ចាស់ប្រភពបង្កើតសំណល់នានា និងប្រជាពលរដ្ឋ មានភារកិច្ចដូចខាងក្រោម៖

- ត្រូវធ្វើការញែកសំរាមទៅតាមប្រភេទដាក់ដោយឡែកពីគ្នា រវាងសំណល់ផ្ទះបាយ (សំរាមសើម) និងសំរាមអាចកែច្នៃបាន (សំរាមស្ងួត) ដោយត្រូវធ្វើការវេចខ្ចប់ដាក់ក្នុងថង់ ឬធុងសំរាមផ្សេងពីគ្នា មិនឱ្យមានការលេចធ្លាយ ឬជ្រាបទឹក និងក្លិនស្អុយ រួចយកទៅដាក់នៅតាមមុខលំនៅឋាន ឬតាមទីតាំងដែលបានកំណត់ដោយរដ្ឋបាលខណ្ឌ សង្កាត់ ឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ល្អ
- សំរាមដែលបានវេចខ្ចប់ហើយ ត្រូវបញ្ចេញឱ្យបានទៀងទាត់ទៅតាមកម្មវិធីប្រមូល និងដឹកជញ្ជូនដែលបានកំណត់។ ក្នុងករណីយកសំរាមមកមិនទាន់រថយន្តដឹកសំរាម គឺមិនត្រូវទុកសំរាមចោលមុខលំនៅឋាន លើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវឡើយ ត្រូវយកសំរាមទាំងនោះទៅរក្សាទុកក្នុងទីតាំងរបស់ខ្លួនជាបណ្តោះអាសន្ន រង់ចាំការបញ្ចេញនៅវេនលើកក្រោយទៀត



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២៦ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ចំពោះការប្រារព្ធពិធីផ្សេងៗ ឬការប្រគុំតន្ត្រីនៅតាមទីសាធារណៈ ម្ចាស់ពិធីត្រូវរៀបចំឱ្យមានធុងសំរាម និងវេចខ្ចប់ ទុកដាក់សំរាម សំណល់រឹងក្នុងធុងឱ្យមានសណ្តាប់ធ្នាប់ មានអនាម័យ និងមានសោភ័ណភាពល្អ
- ហាមដាច់ខាតការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ ប្រឡាយ ឬប្រភពទឹកសាធារណៈ ក្នុងដីឡូត៍ទំនេរ ឬក្នុងដីកម្មសិទ្ធិឯកជន។

២. ចំពោះម្ចាស់ទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ការដ្ឋានសាងសង់ មានភារកិច្ចដូចខាងក្រោម៖

- ត្រូវធ្វើការញែក និងបែងចែកសំណល់អាចកែច្នៃ ឬប្រើប្រាស់ឡើងវិញបាន ដាច់ដោយឡែកពីសំរាម សំណល់រឹងនិងសំណល់គ្រោះថ្នាក់ ដែលត្រូវបោះចោល និងប្រមូលដឹកជញ្ជូនដោយក្រុមហ៊ុនឯកជន
- ត្រូវរៀបចំឱ្យមានទីកន្លែងទុកដាក់សំរាម សំណល់រឹង សំណល់គ្រោះថ្នាក់ដែលបានញែករួច ទៅតាមប្រភេទនីមួយៗ ដើម្បីធានាឱ្យមានអនាម័យ និងសោភ័ណភាពល្អស្អាត ទាំងខាងក្នុង និងជុំវិញទីតាំងរបស់ខ្លួន
- សំណល់ការដ្ឋានសំណង់មានដូចជា កំទេចកំទីដី ថ្ម ឥដ្ឋ ក្បឿង បាយអរ ខ្សាច់... មិនអាចដឹកយកទៅចាក់បំពេញទីកន្លែងណាមួយផ្សេងទៀតបានទេ បើគ្មានការអនុញ្ញាតពីរដ្ឋបាលមូលដ្ឋានជាមុន
- ចំពោះសំណល់ឧស្សាហកម្ម សិប្បកម្ម ការដ្ឋានសំណង់ ជាប្រភេទគ្រោះថ្នាក់មានដូចជា កំទេចក្រណាត់ អេប៉ុង ភក់ កៅស៊ូ កញ្ចក់ សេរ៉ាមិច ម្នាងសិលា ថ្នាំលាប។ល។ ត្រូវប្រមូល និងដឹកជញ្ជូនយកទៅចាក់នៅទីលានចាក់សំណល់ឧស្សាហកម្ម
- ហាមដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ-ប្រឡាយ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជននានា។

៣. ចំពោះក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវលើការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ពីតាមលំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស ទីផ្សារ ទីកន្លែងកំសាន្ត អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានា នៅក្នុងរាជធានីភ្នំពេញឱ្យបានស្អាតជាប្រចាំ
- ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ឱ្យបានច្បាស់លាស់ និងសមស្របតាមស្ថានភាពភូមិសាស្ត្រ ដោយមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរសង្កាត់ ខណ្ឌ និងរដ្ឋបាលរាជធានីភ្នំពេញ
- ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយ និងផ្តល់កម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹង ដល់អាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ប្រជាពលរដ្ឋគ្រប់លំនៅឋាន និងគ្រប់ម្ចាស់ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅក្នុងរាជធានីភ្នំពេញឱ្យបានដឹង ដើម្បីងាយស្រួលក្នុងការបញ្ចេញសំណល់ឱ្យបានស្របគ្នានឹងម៉ោងដឹកជញ្ជូន
- ត្រូវធានាការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទៅកាន់ទីលានទុកដាក់សំរាម សំណល់រឹង កុំឱ្យជ្រុះរាយប៉ាយលើផ្លូវ កុំឱ្យហូរស្រក់ទឹកសំណល់ធ្លាក់មកលើខ្នងផ្លូវ និងត្រូវបោសសម្អាតកន្លែងដែលប្រមូលនោះឱ្យបានស្អាតល្អ
- ត្រូវធានាបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅតាមដងផ្លូវនីមួយៗឱ្យបាន

ស្អាត និងគោរពទៅតាមម៉ោងពេលនៃកម្មវិធីដែលបានកំណត់។ ក្នុងករណីយឺតយ៉ាវមិនបានអនុវត្ត តាមកម្មវិធីម៉ោងពេលកំណត់ នឹងត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច និងទណ្ឌកម្មផ្សេងៗ តាមច្បាប់ជាធរមាន

- ត្រូវរៀបចំឱ្យមានរថយន្តដឹកជញ្ជូន ដែលមានស្លាកសញ្ញាសម្គាល់រថយន្តដឹកសំរាមអាចកែច្នៃបាន (សំរាមស្ងួត) និងសំរាមផ្ទះបាយ (សំរាមសើម) ដោយភ្ជាប់ជាមួយនូវតារាងផែនការ និងកាលវិភាគរថយន្តចេញចូលដឹកជញ្ជូនតាមប្រភេទនីមួយៗឱ្យដាច់ចេញពីគ្នា និងច្បាស់លាស់
- ត្រូវផ្សព្វផ្សាយកម្មវិធី និងកាលវិភាគប្រមូលសំរាម សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ ឱ្យដល់ដៃប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយសហការជាមួយរដ្ឋបាលខណ្ឌ សង្កាត់មានសមត្ថកិច្ច
- ត្រូវរៀបចំដាក់ធុងសំរាមនៅតាមទីធ្លាសាធារណៈ សួនច្បារ និងតាមផ្លូវសាធារណៈសំខាន់ៗឱ្យទៅតាមប្រភេទសំរាម និងសំណល់រឹងនីមួយៗ ។

៤. ការផ្តល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់៖

- ម្ចាស់ទីតាំងនីមួយៗ ត្រូវទទួលយកសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់ ជាមួយក្រុមហ៊ុន ឬអង្គភាព ដែលទទួលបានអាជ្ញាប័ណ្ណប្រមូល និងដឹកជញ្ជូនសំណល់ទាំងនេះ
- ម្ចាស់ទីតាំងទាំងអស់ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់ ត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទុកដាក់សំណល់ទាំងនោះ ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

៥. រដ្ឋបាលខណ្ឌ សង្កាត់ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អប់រំផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ក្នុងការញែក វេចខ្ចប់ ទុកដាក់ និងការបោះចោលសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលាដែលបានកំណត់ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង
- ត្រូវសម្របសម្រួលក្នុងការកំណត់ទីតាំងទុកដាក់សំរាម សំណល់រឹងបណ្តោះអាសន្ន រួមទាំងធុងសំរាមសាធារណៈឱ្យបានសមស្រប ដោយមិនបង្កបញ្ហាប៉ះពាល់ដល់ការធ្វើចរាចរណ៍ សុខុមាលភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- សហការជាមួយមន្ទីរបរិស្ថាន ជួយដាក់ស្លាកសញ្ញាហាមឃាត់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ នៅតាមទីតាំងសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញ
- ត្រូវធានាថាគ្មានសំរាម សំណល់រឹងនៅសេសសល់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយត្រូវធ្វើការតាមដានត្រួតពិនិត្យ និងជំរុញការងារប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងរបស់ក្រុមហ៊ុនផ្តល់សេវាឱ្យអនុវត្តបានទៀងទាត់តាមកម្មវិធី។ ក្នុងករណីក្រុមហ៊ុនផ្តល់សេវា មិនបានគោរពតាមកម្មវិធីដឹកជញ្ជូនរបស់ខ្លួន រាប់ទាំងការដឹកជញ្ជូនដែលធ្វើឱ្យជ្រុះសំរាម ហូរទឹកសំរាមលើដងផ្លូវ និងមានសំរាមសល់គរចោលច្រើន ត្រូវធ្វើសេចក្តីរាយការណ៍មករដ្ឋបាលរាជធានីភ្នំពេញភ្លាមអំពីទីតាំងដែលក្រុមហ៊ុនមិនបានអនុវត្តនោះ ដើម្បីមានវិធានការ

- ដឹកនាំកងកំលាំងនគរបាលខណ្ឌ សង្កាត់ ភ្នាក់ងារអនាម័យ មន្ត្រីបរិស្ថាន ចុះទប់ស្កាត់ ណែនាំ និងពិន័យជាប្រាក់ចំពោះអ្នកចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ និងអ្នកបញ្ចេញសំរាម សំណល់រឹងមកដាក់ក្រៅលំនៅឋាន ខុសទីតាំង និងម៉ោងពេលកំណត់
- ចូលរួមសម្របសម្រួលដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសម្អាត ប្រមូល ដឹកជញ្ជូន និងថ្លៃសេវាដឹកជញ្ជូនសំរាម សំណល់រឹង របស់ប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម សេវាកម្ម មូលដ្ឋានបង្កើតសំណល់ ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានរបស់ខ្លួន
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**៦. មន្ទីរបរិស្ថានរាជធានីភ្នំពេញ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវត្រួតពិនិត្យវឌ្ឍនភាពក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាម ក្នុងការរៀបចំផែនការ កម្មវិធី និងកាលវិភាគនានា ដែលកំណត់ក្នុងសេចក្តីណែនាំនេះ
- ត្រូវរៀបចំផែនការត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុន រួចធ្វើរបាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញ
- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំ ការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំមន្ត្រីទទួលបន្ទុកការងារបរិស្ថានប្រចាំខណ្ឌនីមួយៗ ឱ្យសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ចុះពិនិត្យស្ថានភាពការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងខណ្ឌ សង្កាត់នីមួយៗឱ្យបានជាប្រចាំ និងរាយការណ៍មករដ្ឋបាលខណ្ឌ ដើម្បីរកវិធីដោះស្រាយ
- ត្រូវអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងអនុវត្តវិធានការដាក់ពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន
- ផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ ក្នុងការរៀបចំភ្នាក់ងារពិន័យ ព្រមទាំងធ្វើការអប់រំដល់ភ្នាក់ងារពិន័យអំពីយន្តការ និងនីតិវិធីនៃការចុះអនុវត្តឱ្យមានប្រសិទ្ធភាព។

**៧. យន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍**

ក- ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬក៏ប្រព្រឹត្តល្មើសនឹងចំណុចណាមួយខាងលើ ម្ចាស់ទីតាំង និងក្រុមហ៊ុនផ្តល់សេវាកម្មទាំងអស់នៅក្នុងចំណុច ១, ២ និង ៣ នៃសេចក្តីណែនាំនេះ នឹងត្រូវទទួលការពិន័យអន្តរការណ៍ដូចខាងក្រោម៖

- ពិន័យជាប្រាក់ចាប់ពី ១០.០០០រៀល ដល់ ២.០០០.០០០រៀល (ចាប់ពីមួយម៉ឺនរៀល ដល់ពីរលានរៀល) ដូចមានចែងក្នុងមាត្រា ៣៩-៤៩ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"
- ពិន័យជាប្រាក់ចាប់ពី ១.០០០.០០០រៀល ដល់ ៥០.០០០.០០០រៀល (ចាប់ពីមួយលានរៀល ដល់ហាសិបលានរៀល) ឡើងទៅ នឹងត្រូវបិទអាជីវកម្ម ឬផ្អាកការដ្ឋានសាងសង់ជាបណ្តោះអាសន្ន ក្នុងករណីធ្ងន់ធ្ងរ ដែលមន្ត្រីជំនាញពិនិត្យឃើញថាមានការបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ដូចមានចែងនៅក្នុងមាត្រា២០-២២ នៃច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការ

គ្រប់គ្រងធនធានធម្មជាតិ" ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

- ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន
- ចំពោះបុគ្គលណា ដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះនៅក្នុងរយៈពេល ៣០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី ៦០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល ៩០ថ្ងៃ ត្រូវរៀបចំឯកសារប្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្ដន្ទាទោសទៅតាមច្បាប់ជាធរមាន។

ខ- មន្ទីរបរិស្ថានរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ភ្នាក់ងារអនាម័យ និងស្ថាប័នមានសមត្ថកិច្ចនានា ជាអ្នកអនុវត្តវិធានការពិន័យអន្តរការណ៍ខាងលើ ចំពោះម្ចាស់ទីតាំង ឬបុគ្គលណាដែលបានអនុវត្តខុសនឹងសេចក្ដីណែនាំនេះ។

ទទួលបានសេចក្ដីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាប្រជាពលរដ្ឋ ម្ចាស់ទីតាំង ឬអ្នកទទួលខុសត្រូវ (ក្នុងចំណុច ១ និង ២) ប្រធានក្រុមហ៊ុនផ្ដល់សេវាកម្មសំរាម សំណល់រឹង (ក្នុងចំណុច៣) នៅក្នុងរាជធានីភ្នំពេញទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះឱ្យបានម៉ឺងម៉ាត់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ. ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៩
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

ឃួង ស្រេង

<u>កន្លែងទទួល៖</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  «ដើម្បីជូនជ្រាប»
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
  «ដើម្បីសហការ»
- រដ្ឋបាលខណ្ឌទាំង១២
- មន្ទីរ-អង្គភាពជំនាញចំណុះរដ្ឋបាលរាជធានីភ្នំពេញ
- ក្នុងចំណុច ១, ២ និង ៣
  «ដើម្បីអនុវត្ត»
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  «ដើម្បីផ្សព្វផ្សាយ»
- កាលប្បវត្តិ ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ០៤០ /១៩ សរជណ.ស

# សេចក្តីជូនដំណឹង
## ស្តីពីតម្រៃសេវាថ្មី នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋជាម្ចាស់លំនៅឋាន ក្រុមហ៊ុន រោងចក្រ សហគ្រាស និងទីតាំងប្រកបអាជីវកម្ម-សេវាកម្មគ្រប់ប្រភេទក្នុងរាជធានីភ្នំពេញទាំងអស់បានជ្រាបថា ស្របគ្នាជាមួយនឹងកំណើនផ្ទៃដី កំណើនសេដ្ឋកិច្ច និងកំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ បរិមាណសំរាមក៏មានការកើនឡើងយ៉ាងខ្លាំងផងដែរ ដែលជាបញ្ហាប្រឈមចំពោះមុខសម្រាប់រដ្ឋបាលរាជធានីភ្នំពេញត្រូវធ្វើការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដោយក្នុងនោះតម្រូវឱ្យមានការពង្រីកបន្ថែមទៀតនូវការផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់ឱ្យបានល្អ។ ផ្អែកតាមប្រកាសអន្តរក្រសួង ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ លេខ១៩៥ ប្រកប.ស្ត ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់តម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងដើម្បីជំរុញការអនុវត្តការងារខាងលើ ឱ្យមានប្រសិទ្ធភាព សំដៅធ្វើឱ្យរាជធានីភ្នំពេញមានសោភ័ណភាព អនាម័យ និងបរិស្ថានស្អាត រដ្ឋបាលរាជធានីភ្នំពេញ សូមឱ្យបងប្អូនប្រជាពលរដ្ឋជាម្ចាស់លំនៅឋាន ក្រុមហ៊ុន រោងចក្រ សហគ្រាស និងទីតាំងប្រកបអាជីវកម្ម-សេវាកម្មគ្រប់ប្រភេទក្នុងរាជធានីភ្នំពេញ បង់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមតារាងតម្លៃថ្មី " តារាងកំណត់តម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ " ដូចមានជូនភ្ជាប់ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ នេះតទៅ ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋជាម្ចាស់លំនៅឋាន ក្រុមហ៊ុន រោងចក្រ សហគ្រាស និងទីតាំងប្រកបអាជីវកម្ម-សេវាកម្មគ្រប់ប្រភេទក្នុងរាជធានីភ្នំពេញទាំងអស់មេត្តាជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាព។

ថ្ងៃ សុក្រ ៧ រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៩

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- អគ្គិសនីកម្ពុជា (EDC)

«ដើម្បីជូនជ្រាប»
- រដ្ឋបាលខណ្ឌទាំង១២
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- គ្រប់មន្ទីរ អង្គភាពជុំវិញសាលារាជធានីភ្នំពេញ
- ក្រុមហ៊ុនស៊ីនទ្រី

«ដើម្បីអនុវត្ត»
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

«ដើម្បីជួយផ្សព្វផ្សាយ»
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣ [illegible]
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៧២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

# តារាងកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅរាជធានីភ្នំពេញ

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៨៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| A | ក | លំនៅដ្ឋាន | | | | | | | | |
| AI | I | លំនៅដ្ឋានរស់នៅធម្មតា | | | | | | | | |
| AI-1 | | ១.ផ្ទះល្វែងជាន់ផ្ទាល់ដី | រ/ខែ | 8.740 | 1.900 | 10.600 | 7.360 | 1.600 | 9.000 | ករណីផ្ទះ១ល្វែង មានច្រើនជាន់ ហើយរស់នៅតែ១គ្រួសារគឺគិតតែជាន់ផ្ទាល់ដី ប៉ុន្តែករណីមានច្រើនជាង១គ្រួសារ គឺគិតតាមចំនួនជាន់ដែលគ្រួសារបានរស់នៅ។ |
| AI-2 | | ២.ផ្ទះល្វែងជាន់ទី១ឡើងទៅ | រ/ខែ | 5.700 | 1.900 | 7.600 | 4.800 | 1.600 | 6.400 | |
| AI-3 | | ៣.ផ្ទះឈើធម្មតា | រ/ខែ | 11.780 | 2.280 | 14.100 | 9.920 | 1.920 | 11.800 | |
| AI-4 | | ៤.ភូមិគ្រឹះផ្ទៃដីតូចជាង៣០០ម² | រ/ខែ | 26.980 | 4.560 | 31.500 | 22.720 | 3.840 | 26.600 | |
| AI-5 | | ៥.ភូមិគ្រឹះផ្ទៃដីចាប់ពី៣០០-៦០០ម² | រ/ខែ | 53.580 | 6.840 | 60.400 | 45.120 | 5.760 | 50.900 | |
| AI-6 | | ៦.ភូមិគ្រឹះផ្ទៃដីធំជាង៦០០ម² | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| AII | II | លំនៅដ្ឋានក្នុងបុរី/ក្រុងរណប | | | | | | | | |
| AII-1 | | ១.ផ្ទះល្វែង | រ/ខែ | 11.020 | 1.900 | 12.900 | 9.280 | 1.600 | 10.900 | ករណីផ្ទះ១ល្វែង មានច្រើនជាន់ ហើយរស់នៅតែ១គ្រួសារគឺគិតតែជាន់ផ្ទាល់ដី ប៉ុន្តែករណីមានច្រើនជាង១គ្រួសារ គឺគិតតាមចំនួនជាន់ដែលគ្រួសារបានរស់នៅ។ |
| AII-2 | | ២.វីឡាភ្លោះ | រ/ខែ | 25.840 | 3.800 | 29.600 | 21.760 | 3.200 | 25.000 | |
| AII-3 | | ៣.វីឡាទោលផ្ទៃដីតូចជាង៣០០ម² | រ/ខែ | 35.720 | 4.560 | 40.300 | 30.080 | 3.840 | 33.900 | |
| AII-4 | | ៤.វីឡាទោលផ្ទៃដីចាប់ពី៣០០ម²ឡើង | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | សមាមាត្រគិតតាមចំនួនម៉ែត្រការ៉េ |
| AIII | III | ខុនដូ/អាផាតមិន ( គិតចំនួនយូនីត ) | | | | | | | | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| AIII-1 | | ១.តូចជាង៣បន្ទប់/យូនីត | រ/យូនីត.ខែ | 17.860 | 2.280 | 20.100 | 15.040 | 1.920 | 17.000 | |
| AIII-2 | | ២.ចាប់ពី៣បន្ទប់/យូនីត | រ/យូនីត.ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| AIV | IV | ផ្ទះជួលអោយកម្មករ ( គិតចំនួនបន្ទប់ ) | | | | | | | | |
| AIV-1 | | ១.ផ្ទះ/អាគារជួលអោយកម្មករស្នាក់នៅ | រ/បន្ទប់.ខែ | 4.560 | 1.520 | 6.100 | 3.840 | 1.280 | 5.100 | |
| AV | V | ផ្ទះជួលអោយបរទេសស្នាក់នៅ | | | | | | | | |
| AV-1 | | ១.ផ្ទះជួលអោយបរទេសស្នាក់នៅ | រ/ខែ | ទ្វេគុណ | | | ទ្វេគុណ | | | |
| B | ខ | ទីតាំងអាជីវកម្មទូទៅ | | | | | | | | |
| BI | I | ផ្ទះធ្វើអាជីវកម្មទូទៅ | | | | | | | | លក់ចាប់ហួយ, លក់ដាវ, អារកាខ្វិះ, នំបាវ, ចេករៀន,លក់បារីធុង, លក់សាំងដប, លក់កាតទូរស័ព្ទ , លក់ទឹកអំពៅ, លក់កាហ្វេ, ជាងជួសជុល(ម៉ូតូ/កង្ហារ ម៉ូទ័រ.....ប៉ះកង់ឡាន),ជាងទង, លក់ខោអាវជជុះ, បិតម៉ូតូ, បញ្ចូលបទភ្លេងទូរស័ព្ទ, ជាងកាត់ដេរ, ប្តូរប្រាក់ដាក់ទូរ, កោសជប់ ម៉ាស្សា, ជាងកាត់សក់, គ្រឿងអេតចាយតិចតួច, លាងម៉ូតូ, គ្រូទាយ, ផ្ទះធ្វើម៉ូតូ, លក់ប្រហិតខ្ចៅ ជើងស្លាបមាន់ ងាវ ពងទាអាំង ពងទាកូន, ថ្នាក់ក្រា...។ល។ |
| BI-1 | | ១.ទំហំផ្ទះ១ល្វែង | រ/ខែ | 42.940 | 5.700 | 48.600 | 36.160 | 4.800 | 41.000 | |
| BI-2 | | ២.ទំហំចាប់ពីផ្ទះ២ល្វែងឡើង | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| BII | II | ឱសថស្ថាន | | | | | | | | |
| BII-1 | | ១.ទំហំផ្ទះ១ល្វែង | រ/ខែ | 42.940 | 5.700 | 48.600 | 36.160 | 4.800 | 41.000 | |
| BII-2 | | ២.ទំហំចាប់ពីផ្ទះ២ល្វែងឡើង | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| BIII | III | ភោជនីយដ្ឋាន/អាហារដ្ឋាន | | | | | | | | |
| BIII-1 | | ១.អាហារដ្ឋានផ្ទះ១ល្វែង ( ១ជាន់ ) | រ/ខែ | 58.900 | 7.600 | 66.500 | 49.600 | 6.400 | 56.000 | |
| BIII-2 | | ២.ភោជនីយដ្ឋានផ្ទះ១ល្វែង ( ១ជាន់ ) | រ/ខែ | 98.040 | 12.540 | 110.600 | 82.560 | 10.560 | 93.100 | |
| BIII-3 | | ៣.ភោជនីយដ្ឋាន/អាហារដ្ឋានធំជាង១ល្វែង | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| BIII-4 | | ៤.ភោជនីយដ្ឋានប៊ុសហ្វេ ( គិតផ្ទៃអគារ ) | រ/ម២.ខែ | 1.900 | 380 | 2.300 | 1.600 | 320 | 1.900 | |
| C | គ | សណ្ឋាគារ និងផ្ទះសំណាក់ | | | | | | | | |
| CI | I | បឹងហ្គាឡូ ( គិតចំនួនបន្ទប់ ) | | | | | | | | |
| CI-1 | | ១.បឹងហ្គាឡូ | រ/បន្ទប់.ខែ | 28.500 | 3.800 | 32.300 | 24.000 | 3.200 | 27.200 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| CII | II | សណ្ឋាគារ ( គិតចំនួនបន្ទប់ ) | | | | | | | | |
| CII-1 | | ១.មានអាហារដ្ឋាន | រ/បន្ទប់.ខែ | 21.660 | 3.040 | 24.700 | 18.240 | 2.560 | 20.800 | |
| CII-2 | | ២.គ្មានអាហារដ្ឋាន | រ/បន្ទប់.ខែ | 11.020 | 1.520 | 12.500 | 9.280 | 1.280 | 10.600 | |
| CIII | III | ផ្ទះសំណាក់ ( គិតចំនួនបន្ទប់ ) | | | | | | | | |
| CIII-1 | | ១.ផ្ទះសំណាក់ | រ/បន្ទប់.ខែ | 8.360 | 1.140 | 9.500 | 7.040 | 960 | 8.000 | |
| D | ឃ | មណ្ឌលកំសាន្ត / កីឡា | | | | | | | | |
| DI | I | រង្គសាល-ក្លឹប ( គិតផ្ទៃអគារ ) | | | | | | | | ក្លឹបកីឡា (បុកប៊ៅឡិង, វាយកូនបាល់លើតុ, បាល់ទាត់, បាល់ទះ, តេនីស, ហែលទឹក, ប៊ូលីង, ជិះស្គី, ម៉ាស្សា ស្ទីម សូណា, Play Ground, ហាត់ប្រាណ, ប្រដាល់...)។ល។ |
| DI-1 | | ១.ទំហំតូចជាង២០០ម² | រ/ខែ | 533.520 | 34.200 | 567.700 | 449.280 | 28.800 | 478.100 | |
| DI-2 | | ២.ទំហំចាប់ពី២០០-៤០០ម² | រ/ខែ | 1.067.040 | 68.400 | 1.135.400 | 898.560 | 57.600 | 956.200 | ក្លឹបកំសាន្ត (រង្គសាល, Pub...)។ល។ |
| DI-3 | | ៣.ទំហំធំជាង៤០០ម² | រ/ម២.ខែ | 3.040 | 380 | 3.400 | 2.560 | 320 | 2.900 | |
| DII | II | KTV ( គិតចំនួនបន្ទប់ ) | | | | | | | | |
| DII-1 | | ១.KTV | រ/បន្ទប់.ខែ | 50.160 | 3.420 | 53.600 | 42.240 | 2.880 | 45.100 | |
| DIII | III | បៀហ្គាឌិន/សាច់អាំង | | | | | | | | |
| DIII-1 | | ១.ចំណុះតិចជាង១៥តុ | រ/ខែ | 220.400 | 14.440 | 234.800 | 185.600 | 12.160 | 197.800 | |
| DIII-2 | | ២.ចំណុះចាប់ពី១៥-៣០តុ | រ/ខែ | 440.420 | 28.500 | 468.900 | 370.880 | 24.000 | 394.900 | |
| DIII-3 | | ៣.ចំណុះធំជាង៣០តុ | រ/ខែ | | សមាមាត្រ | | | សមាមាត្រ | | |
| DIV | IV | មហោស្រប/រោងភាពយន្ត | | | | | | | | |
| DIV-1 | | ១.ចំណុះតិចជាង២០០នាក់ | រ/ខែ | 355.680 | 45.600 | 401.300 | 299.520 | 38.400 | 337.900 | |
| DIV-2 | | ២.ចំណុះចាប់ពី២០០-៤០០នាក់ | រ/ខែ | 711.360 | 91.200 | 802.600 | 599.040 | 76.800 | 675.800 | |
| DIV-3 | | ៣.ចំណុះធំជាង៤០០នាក់( គិតចំនួនកៅអី ) | រ/កៅអី.ខែ | 3.040 | 380 | 3.400 | 2.560 | 320 | 2.900 | |
| DV | V | កាស៊ីណូ ( មិនគិតបញ្ចូលភោជនីយដ្ឋាន ក្លឹបកំសាន្តផ្សេងៗ ) | | | | | | | | |
| DV-1 | | ១.ចំណុះតិចជាង២០០នាក់ | រ/ខែ | 2.845.440 | 182.400 | 3.027.800 | 2.396.160 | 153.600 | 2.549.800 | |
| DV-2 | | ២.ចំណុះចាប់ពី២០០-៤០០នាក់ | រ/ខែ | 5.690.880 | 364.800 | 6.055.700 | 4.792.320 | 307.200 | 5.099.500 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| DV-3 | | ៣.ចំណុះចាប់ពី៤០០នាក់ឡើង | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| E | ង | មជ្ឈមណ្ឌលពាណិជ្ជកម្ម/លក់ដូរ | | | | | | | | |
| EI | I | ផ្សារទំនើប ( គិតផ្ទៃអគារ ) | | | | | | | | |
| EI-1 | | ១.អាគារលក់ទំនិញ/ផ្សារទំនើប | រ/ម២.ខែ | 2.280 | 380 | 2.700 | 1.920 | 320 | 2.200 | |
| EIII | III | ហាងទំនិញ ( គិតផ្ទៃអគារ ) | | | | | | | | ហាងលក់ (ខ្សែរស័ព្ទ/អាយធូម, សម្ភារៈកីឡា, សម្ភារៈអគ្គីសនី, សម្ភារៈកីឡា, គ្រឿងអលង្ការ, គ្រឿងសំអាង, វត្ថុបុរាណ/វត្ថុសិល្បៈ, ឆ្លាក់រូប ឬថ្មម៉ាប, សម្ភារៈគ្រឿងសំណង់, លក់/ជួលឧបករណ៍តន្ត្រី, លក់ទំនិញច្រកខ្ចប់, លក់គ្រឿងជ័រ, លក់កង់រថយន្ត, លក់ភេសជ្ជៈ, លក់ផ្កា ត្រូវជាតិ, លក់តែ/កាហ្វេ, កន្លែងបោះដុំ រេងចុំទំនិញ, លក់នាឡិកា, វ៉ែនតា, កែសម្ផស្ស, អ៊ុតសក់, កាត់សក់, ថតរូប, សេវាកម្មហ្វូតូកូពី, បោះពុម្ព, ប្តូររូបិយប័ណ្ណ (ដូរលុយ), កន្លែងលក់គ្រឿងសង្ហារឹម, សម្ភារៈបន្ទប់គេង, សម្ភារៈផ្ទះបាយ, សម្ភារៈក្មេងលេង, កន្លែងលក់ក្រាលព្រំស, សេវាកម្មអ៊ីនធឺណេត, ទីភ្នាក់ងារទេសចរណ៍, បណ្ណាគារ/បណ្ណាល័យ, លក់ម៉ាស៊ីនដេរ, លក់ក្រណាត់, លក់គ្រឿងតុបតែងរថយន្ត, លក់ថ្នាំចិនសែ, លក់សត្វចិញ្ចឹម, លក់កញ្ចក់/អាលុយមីញ៉ូម អ៊ីណុក, លក់ភេសជ្ជៈ, លក់ចំណីសត្វ, លក់ដីសរីរាង្គ, លក់ផ្លែឈើ, លក់បន្លែធម្មជាតិ(Organic), លក់អាហារប៉ូប៉ិន ថែរក្សាសុខភាព, លក់ឧបករណ៍កែសម្ផស្ស, លក់ឧបករណ៍ម៉ាស្សា/កៅអីម៉ាស្សា, សំអាងការ, ហាងបញ្ចាំ, គណនេយ្យករ (សេវាកម្មចុះបញ្ជី ឬពិនិត្យបញ្ជីគណនេយ្យ), ការិយាល័យមេធាវី,សេវាប្រឹក្សាយោបល់, សេវារៀបចំពិធីជប់លៀងនិងពិធីអាពាហ៍ពិពាហ៍, សេវាកម្មបកប្រែភាសា...)។ល។ |
| EIII-1 | | ១.ហាងទំនិញធម្មតា | រ/ម២.ខែ | 1.140 | 380 | 1.500 | 960 | 320 | 1.300 | |
| EIII-2 | | ២.មីនីម៉ាត | រ/ម២.ខែ | 1.140 | 380 | 1.500 | 960 | 320 | 1.300 | |
| EIV | IV | អគារពាណិជ្ជកម្ម ( គិតផ្ទៃអគារ ) | | | | | | | | |
| EIV-1 | | ១.អគារពាណិជ្ជកម្ម | រ/ម២.ខែ | 1.520 | 380 | 1.900 | 1.280 | 320 | 1.600 | |
| F | ច | មន្ទីរពេទ្យ/សុខភាពឯកជន-ស្វយ័ត | | | | | | | | |
| FI | I | មន្ទីរពេទ្យ ( គិតចំនួនគ្រែ ) | | | | | | | | |
| FI-1 | | ១.មន្ទីរពេទ្យ | រ/គ្រែ.ខែ | 16.340 | 2.280 | 18.600 | 13.760 | 1.920 | 15.700 | |
| FII | II | មន្ទីរសម្ភព ( គិតចំនួនគ្រែ ) | | | | | | | | |
| FII-1 | | ១.មន្ទីរសម្ភព | រ/គ្រែ.ខែ | 16.340 | 2.280 | 18.600 | 13.760 | 1.920 | 15.700 | |
| FIII | III | មន្ទីរព្យាបាលជំងឺ ( គិតចំនួនគ្រែ ) | | | | | | | | |
| FIII-1 | | ១.មន្ទីរសំរាកព្យាបាលជំងឺ | រ/គ្រែ.ខែ | 11.020 | 1.520 | 12.500 | 9.280 | 1.280 | 10.600 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| FIV | IV | បន្ទប់ពិគ្រោះជំងឺ | | | | | | | | |
| FIV-1 | | ១.បន្ទប់ពិគ្រោះជំងឺ | ៛/ខែ | 28.500 | 3.800 | 32.300 | 24.000 | 3.200 | 27.200 | |
| G | ឆ | គ្រឹះស្ថានអប់រំឯកជន-ស្វយ័ត/អង្គការ | | | | | | | | |
| GI | I | សកល/មហាវិទ្យាល័យ | | | | | | | | |
| GI-1 | | ១.តិចជាង១០បន្ទប់ | ៛/ខែ | 240.160 | 51.300 | 291.500 | 202.240 | 43.200 | 245.400 | |
| GI-2 | | ២.ចាប់ពី១០ដល់៣០បន្ទប់ | ៛/ខែ | 720.480 | 153.900 | 874.400 | 606.720 | 129.600 | 736.300 | |
| GI-3 | | ៣.ច្រើនជាង៣០បន្ទប់ | ៛/ខែ | | សមាមាត្រ | | | សមាមាត្រ | | |
| GII | II | សាលារៀនចំណេះទូទៅ | | | | | | | | |
| GII-1 | | ១.តិចជាង១០បន្ទប់ | ៛/ខែ | 160.360 | 34.200 | 194.600 | 135.040 | 28.800 | 163.800 | |
| GII-2 | | ២.ចាប់ពី១០ដល់៣០បន្ទប់ | ៛/ខែ | 480.320 | 102.600 | 582.900 | 404.480 | 86.400 | 490.900 | |
| GII-3 | | ៣.ច្រើនជាង៣០បន្ទប់ | ៛/ខែ | | សមាមាត្រ | | | សមាមាត្រ | | |
| GII | II | សាលាអង្គការមិនយកថ្លៃសិក្សា | | | | | | | | |
| GII-1 | | ១.តិចជាង១០បន្ទប់ | ៛/ខែ | 120.080 | 25.840 | 145.900 | 101.120 | 21.760 | 122.900 | |
| GII-2 | | ២.ចាប់ពី១០បន្ទប់ឡើង | ៛/ខែ | | សមាមាត្រ | | | សមាមាត្រ | | |
| GIII | III | សាលារៀនកម្រិតអន្តរជាតិ | | | | | | | | |
| GIII-1 | | ១.តិចជាង១០បន្ទប់ | ៛/ខែ | 600.400 | 51.300 | 651.700 | 505.600 | 43.200 | 548.800 | |
| GIII-2 | | ២.ចាប់ពី១០-២០បន្ទប់ | ៛/ខែ | 1.200.420 | 102.600 | 1.303.000 | 1.010.880 | 86.400 | 1.097.300 | |
| GIII-3 | | ៣.ច្រើនជាង២០បន្ទប់ | ៛/ខែ | | សមាមាត្រ | | | សមាមាត្រ | | |
| H | ជ | គ្រឹះស្ថានអប់រំរដ្ឋ-ស្វយ័ត | | | | | | | | |
| HI-1 | | ១. សាលាចំណេះទូទៅ | ៛/ខែ | 266.760 | 68.400 | 335.200 | 224.640 | 57.600 | 282.200 | |
| I | ឈ | ក្រុមហ៊ុនឯកជន | | | | | | | | |
| I.I | I | ក្រុមហ៊ុនឯកជនទូទៅ | | | | | | | | |
| I.I-1 | | ១.បុគ្គលិកតិចជាង១៥នាក់ | ៛/ខែ | 126.920 | 8.360 | 135.300 | 106.880 | 7.040 | 113.900 | |
| I.I-2 | | ២.បុគ្គលិកចាប់ពី១៥-៥០នាក់ | ៛/ខែ | 422.560 | 27.360 | 449.900 | 355.840 | 23.040 | 378.900 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| I.I-3 | | ៣.បុគ្គលិកលើសពី៥០នាក់ | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| I.II | II | ធនាគារ/គ្រឹះស្ថានហិរញ្ញវត្ថុ/មីក្រូហិរញ្ញវត្ថុ | | | | | | | | |
| I.II-1 | | ១.បុគ្គលិកតិចជាង២៥នាក់ | រ/ខែ | 344.660 | 22.420 | 367.100 | 290.240 | 18.880 | 309.100 | |
| I.II-2 | | ២.បុគ្គលិកចាប់ពី២៥-៥០នាក់ | រ/ខែ | 689.320 | 44.460 | 733.800 | 580.480 | 37.440 | 617.900 | |
| I.II-3 | | ៣.បុគ្គលិកលើសពី៥០នាក់ | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| J | ញ | ស្ថានីយ-ដេប៉ូប្រេងឥន្ធនៈ | | | | | | | | |
| JI | I | មានកន្លែងលាងរថយន្តឬហាងទំនិញ | រ/ខែ | 293.740 | 19.000 | 312.700 | 247.360 | 16.000 | 263.400 | |
| JII | II | គ្មានកន្លែងលាងរថយន្តឬហាងទំនិញ | រ/ខែ | 121.220 | 7.980 | 129.200 | 102.080 | 6.720 | 108.800 | |
| K | ដ | ទីតាំងស្តុកទំនិញ/ផ្ទះទំនិញ | | | | | | | | |
| KI | I | ១.កំពង់ផែ ( គិតផ្ទៃដី ) | | | | | | | | |
| KI-1 | | ១.កំពង់ផែ | រ/ម២.ខែ | 3.040 | 380 | 3.400 | 2.560 | 320 | 2.900 | |
| KII | II | ស្ថានីយរថភ្លើង ( គិតផ្ទៃអគារ ) | | | | | | | | |
| KII-1 | | ១.ស្ថានីយរថភ្លើង | រ/ម២.ខែ | 3.040 | 380 | 3.400 | 2.560 | 320 | 2.900 | |
| KIII | III | ចំណតរថយន្តដឹកអ្នកដំណើរ ( គិតផ្ទៃអគារ ) | | | | | | | | |
| KIII-1 | | ១.ចំណតរថយន្តដឹកអ្នកដំណើរ | រ/ម២.ខែ | 3.040 | 380 | 3.400 | 2.560 | 320 | 2.900 | |
| KIV | IV | ព្រលានយន្តហោះ ( គិតផ្ទៃអគារ ) | | | | | | | | |
| KIV-1 | | ១.ព្រលានយន្តហោះ | រ/ម២.ខែ | 3.800 | 380 | 4.200 | 3.200 | 320 | 3.500 | |
| KV | V | ផែស្ងួត ( គិតផ្ទៃដី ) | | | | | | | | |
| KV-1 | | ១.ទំហំតូចជាង ១០០០០ម$^{២}$ | រ/ខែ | 711.360 | 45.600 | 757.000 | 599.040 | 38.400 | 637.400 | |
| KV-2 | | ២.ទំហំចាប់ពី ១០០០០-២០០០០ម$^{២}$ | រ/ខែ | 1.422.720 | 91.200 | 1.513.900 | 1.198.080 | 76.800 | 1.274.900 | |
| KV-3 | | ៣.ទំហំធំជាង ២០០០០ម$^{២}$ | រ/ម២.ខែ | 760 | 380 | 1.100 | 640 | 320 | 1.000 | |
| KVI | VI | ឃ្លាំងស្តុកទំនិញ ( គិតផ្ទៃឃ្លាំង ) | | | | | | | | |
| KVI-1 | | ១.ទំហំតូចជាង ៣០០ម$^{២}$ | រ/ខែ | 106.780 | 6.840 | 113.600 | 89.920 | 5.760 | 95.700 | |
| KVI-2 | | ២.ទំហំចាប់ពី ៣០០ដល់៦០០ម$^{២}$ | រ/ខែ | 213.560 | 13.680 | 227.200 | 179.840 | 11.520 | 191.400 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| KVI-3 | | ៣.ទំហំធំជាង ៦០០ម² | រ/ម២.ខែ | 380 | 380 | 800 | 320 | 320 | 600 | |
| KVII | VII | ឃ្លាំងស្តុកប្រេងឥន្ធនៈ | | | | | | | | |
| KVII-1 | | ១.ពោងស្តុកតិចជាង ៣ | រ/ខែ | 640.300 | 41.040 | 681.300 | 539.200 | 34.560 | 573.800 | |
| KVII-2 | | ២.ពោងស្តុកចាប់ពី ៣-៤ | រ/ខែ | 1.280.600 | 82.060 | 1.362.700 | 1.078.400 | 69.120 | 1.147.500 | |
| KVII-3 | | ៣.ពោងស្តុកលើសពី ៤ | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| KVIII | VIII | ចំណតរថយន្តដឹក/ផ្ទេរទំនិញ ( គិតផ្ទៃដី ) | | | | | | | | |
| KVIII-1 | | ១.ទំហំតូចជាង ៥០០ម² | រ/ខែ | 142.500 | 9.120 | 151.600 | 120.000 | 7.680 | 127.700 | |
| KVIII-2 | | ២.ទំហំចាប់ពី ៥០០-១៥០០ម² | រ/ខែ | 427.120 | 27.360 | 454.500 | 359.680 | 23.040 | 382.700 | |
| KVIII-3 | | ៣.ទំហំធំជាង ១៥០០ម² | រ/ម២.ខែ | 380 | 380 | 800 | 320 | 320 | 600 | |
| KIX | IX | អគារ/ឃ្លាំងលក់រថយន្ត-ម៉ូតូ ( គិតផ្ទៃអគារ ) | | | | | | | | |
| KIX-1 | | ១.ទំហំតូចជាង ២០០ម² | រ/ខែ | 62.320 | 4.180 | 66.500 | 52.480 | 3.520 | 56.000 | |
| KIX-2 | | ២.ទំហំចាប់ពី ២០០-៤០០ម² | រ/ខែ | 124.640 | 7.980 | 132.600 | 104.960 | 6.720 | 111.700 | |
| KIX-3 | | ៣.ទំហំធំជាង ៤០០ម² | រ/ម២.ខែ | 380 | 380 | 800 | 320 | 320 | 600 | |
| L | ឋ | រោងចក្រ/សិប្បកម្ម | | | | | | | | |
| LI | I | រោងចក្រ/ឧស្សាហកម្ម | | | | | | | | |
| LI-1 | | ១.កម្មករ/បុគ្គលិកក្រោម ២៥០នាក់ | រ/ខែ | 889.200 | 57.000 | 946.200 | 748.800 | 48.000 | 796.800 | |
| LI-2 | | ២.កម្មករ/បុគ្គលិកចាប់ពី ២៥០-៥០០នាក់ | រ/ខែ | 1.778.400 | 114.000 | 1.892.400 | 1.497.600 | 96.000 | 1.593.600 | |
| LI-3 | | ៣.បុគ្គលិក/កម្មករលើសពី ៥០០នាក់ | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| LII | II | សិប្បកម្ម/ឧស្សាហកម្មធុនស្រាល | | | | | | | | |
| LII-1 | | ១.បុគ្គលិក/កម្មករក្រោម ៥០នាក់ | រ/ខែ | 177.840 | 11.400 | 189.200 | 149.760 | 9.600 | 159.400 | |
| LII-2 | | ២.បុគ្គលិក/កម្មករលើសពី ៥០នាក់ | រ/ខែ | សមាមាត្រ | | | សមាមាត្រ | | | |
| M | ឌ | ស្ថានទូត-កុងស៊ុល-អង្គការ | | | | | | | | |
| MI | I | ស្ថានទូត-កុងស៊ុល ( គិតផ្ទៃដី ) | | | | | | | | |
| MI-1 | | ១.តូចជាង ១២០០ម² | រ/ខែ | 786.960 | 50.540 | 837.500 | 662.720 | 42.560 | 705.300 | |

| កូដ | ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់រឹង | មាត្រដ្ឋាន | រាជធានីភ្នំពេញ | | | | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ៩៦ សង្កាត់ | | | ២០ សង្កាត់ថ្មី | | | |
| | | | | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | សំអាត ប្រមូលដឹកជញ្ជូន | ទីលាន | គ្រប់គ្រង (សរុប) | |
| MI-2 | | ១.ធំជាង ១២០០ម² | រ/ម២.ខែ | 1.140 | 380 | 1.500 | 960 | 320 | 1.300 | |
| MII | II | អង្គការមិនមែនរដ្ឋាភិបាល | រ/ខែ | 444.600 | 28.500 | 473.100 | 374.400 | 24.000 | 398.400 | |
| N | ឍ | ស្ថាប័ន/អង្គភាពរដ្ឋ | | | | | | | | |
| NI | I | ក្រសួង/ស្ថាប័ន | រ/ខែ | 711.360 | 91.200 | 802.600 | 599.040 | 76.800 | 675.800 | |
| NII | II | មន្ទីរអង្គភាពរដ្ឋ | រ/ខែ | 106.780 | 13.680 | 120.500 | 89.920 | 11.520 | 101.400 | |
| O | ណ | ផ្សេងៗ | | | | | | | | |
| OI | I | ការធ្វើកម្មវិធីនៅទីសាធារណៈ | | | | | | | | |
| OI-1 | | ១.កម្មវិធីអ្នកចូលរួមតិចជាង ១០០០នាក់/ថ្ងៃ | រ/ថ្ងៃ | 355.680 | 22.800 | 378.500 | 299.520 | 19.200 | 318.700 | |
| OI-2 | | ២.កម្មវិធីអ្នកចូលរួមចាប់ពី ១០០០-១៥០០នាក់/ថ្ងៃ | រ/ថ្ងៃ | 533.520 | 34.200 | 567.700 | 449.280 | 28.800 | 478.100 | |
| OI-3 | | ៣.កម្មវិធីអ្នកចូលរួមលើសពី ១៥០០នាក់/ថ្ងៃ | រ/ថ្ងៃ | សមាមាត្រ | | | សមាមាត្រ | | | |
| OI-4 | | ៤.ការប្រគុំតន្ត្រីក្នុង១ថ្ងៃ | រ/ថ្ងៃ | 1.067.040 | 68.400 | 1.135.400 | 898.560 | 57.600 | 956.200 | |
| OII | II | ការលក់ដូរចល័តតាមដងផ្លូវ ( ក្នុង១ថ្ងៃ ) | | | | | | | | |
| OII-1 | | ១.ការលក់ដូរផ្សេងៗតាមដងផ្លូវ | រ/ថ្ងៃ | 380 | 380 | 800 | 320 | 320 | 600 | |
| OIII | III | ការដ្ឋានសាងសង់ផ្សេងៗ (គិតបរិមាណ) | | | | | | | | |
| OIII-1 | | ១.បញ្ចេញសំណល់រឹងចេញពីការដ្ឋានដោយប្រើប្រាស់ក្រុមហ៊ុនផ្ដល់សេវាប្រមូល និងដឹកជញ្ជូន | រ/តោន | 148.200 | 19.000 | 167.200 | 124.800 | 16.000 | 140.800 | |

* សំគាល់ ៖

២០សង្កាត់ថ្មី គឺជាសង្កាត់ដែលបានផ្ទេរពីរដ្ឋបាលខេត្តកណ្ដាល ។

ថ្ងៃ អង្គារ [illegible] ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៩

# របាយការណ៍
# បូកសរុបលទ្ធផលការងារឆ្នាំ ២០១៨
# និង ទិសដៅការងារឆ្នាំ ២០១៩

## I. សេចក្តីផ្តើម

ក្រុមហ៊ុនស៊ីនទ្រី បានទទួលសិទ្ធិវិនិយោគលើសេវាកម្មសំអាត ប្រមូល និងដឹកជញ្ជូនសំណល់រឹង (សំរាម) ពីសាលារាជធានីភ្នំពេញ ចាប់ពីខែសីហា ឆ្នាំ២០០២ ។

ក្រុមហ៊ុនបានខិតខំបំពេញការងារតាមកាតព្វកិច្ចរបស់ខ្លួន នឹងគួរអោយមោទនភាពក្នុងការថែរក្សាបរិស្ថានស្អាតក្នុងរាជធានី ទោះបីមានការចោល និងបញ្ចេញសំរាម ២៤ម៉ោង ឥតឈប់ឈរក៏ដោយ ។ ជាមួយគ្នានេះដែរ ចំពោះការថែរក្សាទីក្រុងស្អាតជានិរន្ត អាស្រ័យដោយមានការចូលរួមសហការពីប្រជាពលរដ្ឋ ជាមួយការវេចខ្ចប់ទុកដាក់សំរាម អោយបានត្រឹមត្រូវ និងសាលារាជធានីភ្នំពេញ ផ្តល់នូវការអប់រំផ្សព្វផ្សាយ ចាត់វិធានការទប់ស្កាត់ការចោលសំរាម នៅទីសាធារណៈ និយាយជារួមសំអាតរាជធានីគឺយើងទាំងអស់គ្នា ។ ហើយក្រុមហ៊ុនបានបែងចែកកំលាំងការងារជាពីរវេណ គឺវេណពេលយប់ និងវេណពេលថ្ងៃ។

ក្រុមហ៊ុនបានបង្កើនប្រសិទ្ធិភាព លើសេវាកម្មឱ្យកាន់តែប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ដោយបែងចែកការងារប្រតិបត្តិការផ្សេងពីគ្នា គឺការបោសសំអាតតាមដងមហាវិថី និងវិថីនានា និងការប្រមូលសំរាមនៅតាមទីផ្សារ ផ្ទះ ភោជនីយដ្ឋាន និងតំបន់អាជីវកម្មនានា ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនបាននឹងកំពុងតែធ្វើការងារយ៉ាងហ្មត់ចត់ ដើម្បីកែលំអប្រព័ន្ធផ្តល់សេវាកម្មឱ្យកាន់តែប្រសើរ ដោយប្រើនូវធនធានឱ្យចំទិសដៅ និងតាមឯកទេសសំរាប់តម្រូវការនៃការងារជាក់លាក់ ។

## II. រចនាសម្ព័ន្ធគ្រប់គ្រង

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ក្នុងនោះមានការិយាល័យសរុបទាំងអស់ចំនួន ០៦ ការិយាល័យ រួមមានការិយាល័យរដ្ឋបាល និងធនធានមនុស្ស ការិយាល័យហិរញ្ញវត្ថុ ការិយាល័យព័ត៌មានវិទ្យា ការិយាល័យអតិថិជន ការិយាល័យសំអាតក្រុង ការិយាល័យយានដ្ឋាន និងផ្គត់ផ្គង់ ។

## III. លទ្ធផលក្រុមហ៊ុនបានអនុវត្ត និងបង្កើតដូចជា

### ក. ការអភិវឌ្ឍន៍របស់ក្រុមហ៊ុន

បើពិនិត្យមើលកំលាំងពលកម្ម និងសម្ភារៈ យើងសង្កេតឃើញថា ក្រុមហ៊ុនមានការកើនឡើងចំនួនកំលាំងពលកម្ម ១១៨នាក់ ធៀបនឹងឆ្នាំ២០១៧ និងកើនឡើងចំនួន ១៦៧នាក់ ធៀបនឹងឆ្នាំ២០១៦ ចំណែកចំនួនរថយន្តកើនឡើងចំនួន ៨៦គ្រឿង ធៀបនឹងឆ្នាំ២០១៧ និងកើនឡើងចំនួន ១២៨គ្រឿង ធៀបនឹងឆ្នាំ២០១៦ រទេះដឹកសំរាមកើន ២២គ្រឿង ធៀបនឹងឆ្នាំ២០១៧ ធុងដាំស្ទូរថយចុះ ០១ធុង ដោយសារក្នុងឆ្នាំ២០១៧នេះ ទីតាំងមួយចំនួនត្រូវបានដកធុងដាំស្ទូរចេញឈប់អោយមាន។ ធុងស្មាច់ចាស់ ធុងសំរាមថ្មីដាក់តាមសួនច្បារថយចុះ៨០ធុង ដោយសារធុងសេរីនេះយើងលែងប្រើបន្តទៀតនិងធុងអ្នកបោសថយ១៣ធុង។



អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧
E-mail : info@cintri.com.kh / Website : www.cintri.com.kh

IAS-ANZ
ISO 9001:2008 Cert. No.218400

ខាងក្រោមនេះជាតារាងឧបករណ៍សំភារៈប្រើប្រាស់ និងចំនួនបុគ្គលិក-កម្មករ

| ល.រ | ឧបករណ៍សំភារៈ និងកំលាំងពលកម្ម | 2016 | 2017 | 2018 |
|---|---|---|---|---|
| 1 | បុគ្គលិក-កម្មករ | 2237 | 2290 | 2404 |
| 2 | រថយន្តដឹកសំរាមគ្រប់ខ្នាត (compactor) | 317 | 359 | 445 |
| 3 | ហ្សាស៊ែរ (គ្រឿងចក្រសំរាប់ចូកសំរាមដេប៉ូធំៗ) | 13 | 15 | 17 |
| 4 | រថយន្តបោស | 12 | 9 | 17 |
| 5 | រទេះដឹកសំរាម | 260 | 262 | 284 |
| 6 | ធុងដាំស្ទ័រ | 76 | 74 | 73 |
| 7 | ធុងស្មាច់ចាស់+ធុងសំរាមថ្មីដាក់តាមសួនច្បារ | 61 | 40 | 0 |
| 8 | ធុងសំរាមចំណុះ ១៨០លីត្រ សំរាប់កម្មករបោស | 352 | 362 | 349 |

## ខ. ទំងន់សំរាមដែលរថយន្តដឹកចូលទីលានប្រចាំខែ

ចំពោះខែធ្នូ ឆ្នាំ២០១៨ ពុំទាន់ទទួលបានទិន្នន័យសំរាមចូលចាក់ទីលាននោះទេ ហើយជាមធ្យមក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនអាចប្រមូលបានបរិមាណ ៧៧,៦៨៣តោន ក្នុងមួយខែ និងមានកំនើនមធ្យមស្មើនឹង ១៨% ។

| ល.រ | ខែ | ទំងន់សំរាម(តោន) | | | | |
|---|---|---|---|---|---|---|
| | | 2016 | 2017 | 2018 | 2016-2017 | 2017-2018 |
| 1 | មករា | 56,614 | 63,292 | 75,452 | 12% | 19% |
| 2 | កុម្ភៈ | 52,333 | 57,251 | 69,165 | 9% | 21% |
| 3 | មីនា | 56,417 | 65,934 | 78,546 | 17% | 19% |
| 4 | មេសា | 48,479 | 60,219 | 68,852 | 24% | 14% |
| 5 | ឧសភា | 58,170 | 71,665 | 84,011 | 23% | 17% |
| 6 | មិថុនា | 59,135 | 69,002 | 81,553 | 17% | 18% |
| 7 | កក្កដា | 61,920 | 69,266 | 74,852 | 12% | 8% |
| 8 | សីហា | 62,062 | 70,127 | 84,143 | 13% | 20% |
| 9 | កញ្ញា | 60,081 | 62,291 | 80,194 | 4% | 29% |
| 10 | តុលា | 61,266 | 71,654 | 77,132 | 17% | 8% |
| 11 | វិច្ឆិកា | 61,351 | 66,234 | 80,611 | 8% | 22% |
| 12 | ធ្នូ | 62,787 | 65,750 | N/A | 5% | N/A |
| **មធ្យមភាគ** | | **58,385** | **66,057** | **77,683** | **13%** | **18%** |
| **ចំនួនសរុប** | | **700,615** | **792,685** | **854,510** | | |






អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧

គ. តំបន់សេវា និងការពង្រីកសេវាបន្ថែម

បច្ចុប្បន្នក្រុមហ៊ុនស៊ីនទ្រីបានគ្រប់ដណ្តប់សេវាសំអាត និងប្រមូលប្រមាណ ៩៨% ស្មើនឹង ១០៣សង្កាត់ លើចំនួនសង្កាត់ ១០៥សង្កាត់ (១០៣/១០៥) ក្នុងរាជធានីភ្នំពេញ។ ទិន្នន័យនេះ គឺលើសពីឆ្នាំមុនចំនួន ០២សង្កាត់ ដែលក្នុងឆ្នាំ២០១៧ មានតែ ១០១សង្កាត់ ប៉ុណ្ណោះ។ ក្នុងនោះផងដែរ ខណ្ឌចំនួន ៤ ក្នុងរាជធានី ( ដូនពេញ ចំការមន ទួលគោក និង ៧ មករា ) ទទួលបាននូវសេវាគ្រប់ដណ្តប់ ១០០% ស្មើនឹង ៤៥សង្កាត់ ហើយខណ្ឌ ៨ទៀត នៅជាយរាជធានីបានទទួលសេវា ១០០% តែសង្កាត់ណាដែលមានតម្រូវការប្រមូលសំរាម ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់តែប៉ុណ្ណោះ។ ចំណែកសង្កាត់មួយចំនួនដែលពុំទទួលបានសេវាមាន សង្កាត់កោះដាច់ និងឪឡោក ដោយសារតែមិនមានតម្រូវការ និងស្ថានភាពទីតាំង និងគោលដៅ។




ឃ. សកម្មភាពនិងលទ្ធផលការងារ

មួយឆ្នាំកន្លងទៅនេះ ក្រុមហ៊ុនស៊ីនទ្រីបានចូលរួមអនុវត្តការងារជាច្រើនក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងថែរក្សាសោភ័ណភាព និងសំអាតរាជធានី ។ សរុបរួមយើងឃើញថាសមិទ្ធផលការងារទាំងនោះគឺទទួលបានជោគជ័យជាច្រើន និងខ្លះទៀតក៏ជួបឧបសគ្គផងដែរ សកម្មភាពទាំងនោះរួមមាន ៖

១. សហការជាមួយភ្នាក់ងារអនាម័យចល័តតាមសង្កាត់នីមួយៗ

ភ្នាក់ងារអនាម័យចល័តតាមសង្កាត់ ក្នុងមួយសង្កាត់ ០២នាក់ នៅតាមខណ្ឌនីមួយៗបានសហការធ្វើការរួមគ្នាជាមួយតំណាងក្រុមហ៊ុនតាមខណ្ឌដើម្បី ៖


អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧

- ❖ ចុះសហការជាមួយប្រធានភូមិក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីអនុវត្តនូវភារៈកិច្ចដូចខាងក្រោម៖
  - ផ្សព្វផ្សាយពីកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមដល់ផ្ទះប្រជាពលរដ្ឋ ។
  - ផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ និងអាជីវករ សេវាករ អោយចេះញែក វេចខ្ចប់ និងទុកដាក់សំរាមអោយបានត្រឹមត្រូវតាមម៉ោងពេល និងទីកន្លែងកំណត់តាមរូបភាពឃោសនាតាមឃោសនសព្ទ ឬចែកលិខិតប័ណ្ណអប់រំតាមលំនៅដ្ឋាន និងនៅតាមទីតាំងមួយចំនួនដូចជាទីផ្សារ ចំណតរថយន្ត កន្លែងកំសាន្ត សួនច្បារ និងតាមភោជនីយដ្ឋាន។
  - ចុះពិនិត្យមើលទីតាំងគំនរសំរាម ដែលប្រជាពលរដ្ឋបោះចោល ខុសម៉ោងពេលកំណត់ និងគំនរសំរាមគរសល់ជាយូរមកហើយនៅតាមដងផ្លូវសាធារណៈ ។
  - ទទួលខុសត្រូវថែរក្សា ការពារទីតាំងដេប៉ូសំរាមដែលបានសម្អាតរួច កុំអោយកើតមានឡើងវិញ ។
- ❖ ធ្វើការដាក់ពិន័យអ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងខុសពីការណែនាំរបស់អាជ្ញាធរ មូលដ្ឋានដោយអនុវត្តតាមខ្លឹមសារ នៃអនុក្រឹត្រលេខ ១១៣ អនក្រ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ។

## ២. ការបង្កើនបរិមាណរថយន្តប្រមូលសំរាម

ក្នុងឆ្នាំ២០១៨នេះ ក្រុមហ៊ុនបានទិញរថយន្តថ្មីៗបន្ថែម ដើម្បីប្តូររថយន្តចាស់ៗចេញ ។ យើងបានបញ្ចូលរថយន្តប្រមូលសំរាម និងគ្រឿងចក្របន្ថែមសរុបចំនួន ៨៦គ្រឿង ដើម្បីពង្រឹងសេវាប្រមូល និងដឹកជញ្ជូនសំរាមបច្ចុប្បន្ន និងដើម្បីឆ្លើយតបចំពោះការពង្រីកតំបន់សេវាថ្មី។

## ៣. ការរៀបចំផែនការណ៍បុណ្យជាតិធំៗ

រៀងរាល់កម្មវិធី រឺបុណ្យជាតិធំៗ ក្រុមហ៊ុនតែងរៀបចំផែនការណ៍ និងអនុវត្តការសំអាត ប្រមូល និងដឹកជញ្ជូនបានយ៉ាងជោគជ័យ ជាក់ស្តែងក្នុងឆ្នាំ២០១៨ ដូចជាកម្មវិធីបុណ្យចូលឆ្នាំខ្មែរ ភ្ជុំបិណ្ឌ និងបុណ្យអុំទូកជាដើម ។ ការជោគជ័យនេះ ក៏អាស្រ័យលើការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរតាមមូលដ្ឋានផងដែរ ក្នុងការសហការ និងសម្រួលគ្នាទៅវិញទៅមក ។ ហើយក្នុងនោះ ក្រុមហ៊ុនក៏បានរៀបចំកម្មវិធីបញ្ជ្រាបការយល់ដឹង លើការទុកដាក់ និងវេចខ្ចប់សំរាម ដោយបំផុសស្មារតីប្រជាពលរដ្ឋតាមរយៈការសំណូមពរទៅអាជ្ញាធរមូលដ្ឋាន ក៏ដូចជាតាមប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីជាសារអប់រំដល់ប្រជាពលរដ្ឋអោយចេះទុកដាក់សំរាមអោយបានត្រឹមត្រូវ ។ កម្មវិធីនេះមានអត្ថប្រយោជន៍ជាច្រើនដល់សង្គមជាពិសេសអ្នកចូលរួមក្នុងកម្មវិធីនេះ អោយមានភាពទទួលខុសត្រូវចំពោះកាកសំណល់ (សំរាម) របស់ខ្លួន និងជាគំរូល្អមួយសម្រាប់អោយពួកគាត់យល់ និងអនុវត្តលើការគ្រប់គ្រងសំរាមអោយមានប្រសិទ្ធភាពខ្ពស់ ។


អគារលេខ ៨៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ; ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧
E-mail : info@cintri.com.kh /Web...

## ៤. ការបំបាត់ដេប៉ូសំរាមអនាធិបតេយ្យ

| ខណ្ឌ | បំបាត់ដេប៉ូ |
|---|---|
| ៧មករា | បានសហការជាមួយអាជ្ញាធរលុបបំបាត់អស់តាំងពីចុងឆ្នាំ២០១៦ |
| ចំការមន | បានសហការជាមួយអាជ្ញាធរលុបបំបាត់អស់តាំងពីចុងឆ្នាំ២០១៨ |
| ដូនពេញ | បានសហការជាមួយអាជ្ញាធរលុបបំបាត់អស់តាំងពីចុងឆ្នាំ២០១៧ |
| ទួលគោក | បានសហការជាមួយអាជ្ញាធរលុបបំបាត់អស់តាំងពីចុងឆ្នាំ២០១៧ |
| ពោធិ៍សែនជ័យ | ៨ កន្លែងក្នុងចំនោម ២៦កន្លែង |
| ដង្កោ | បានសហការជាមួយអាជ្ញាធរលុបបំបាត់អស់តាំងពីចុងឆ្នាំ២០១៨ |
| សែនសុខ | ១០ កន្លែងក្នុងចំនោម ១៩កន្លែង |
| ព្រែកព្នៅ | |
| ឫស្សីកែវ | ២៨ កន្លែងក្នុងចំនោម ៣៩កន្លែង |
| ជ្រោយចង្វារ | ៩ កន្លែងក្នុងចំនោម ១៦កន្លែង |
| មានជ័យ | ៨ កន្លែងក្នុងចំនោម ១០កន្លែង |
| ច្បារអំពៅ | |
| សរុបបំបាត់បាន | ៥៥ ទីតាំង |

## ៥. ការចូលរួមការងារសង្គមនិងការងារខាងក្រៅ

ក្នុងទស្សនៈចែករំលែក និងសហការគ្នាដើម្បីរាជធានីស្អាតនៅឆ្នាំ២០១៨នេះ ក្រុមហ៊ុនស៊ីនទ្រី បានបង្កើត/ចូលរួម សកម្មភាពជាច្រើនក្នុងសង្គម ដើម្បីបើកទូលាយក្នុងការចែកចាយបទពិសោធន៍ផ្សេងៗ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសំរាម ការបង្កើតព្រឹត្តិការណ៍បញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋលើផ្នែកបរិស្ថានជាដើម ។ ដូចនេះសកម្មភាពទាំងនោះ រួមមានដូចខាងក្រោម ៖

- **ក្រុមហ៊ុនបានសហការជាមួយនិងសាលាខណ្ឌ និងមន្ទីរបរិស្ថានខណ្ឌទាំង១២ ៖**
  ចុះធ្វើទិវាបរិស្ថាន ដោយដាក់កំលាំង និងគ្រឿងចក្រធ្វើការបោស សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម តាមតំបន់កខ្វក់ខ្លាំង តំបន់មានដេប៉ូសំរាមអនាធិប្បតេយ្យ ដែលបងប្អូនប្រជាពលរដ្ឋបញ្ចេញសំរាមខុសកម្មវិធីប្រមូល ដើម្បីធ្វើការពញ្ញាក់អារម្មណ៍ ក៏ដូចជាការដាស់តឿន អប់រំទៅដល់បងប្អូនប្រជាពលរដ្ឋស្តីពីការទុកដាក់សំរាម និងការបញ្ចេញសំរាមអោយត្រឹមត្រូវតាមកម្មវិធី ។
- **ក្រុមហ៊ុនបានអនុញ្ញាតអោយនិស្សិតមកពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ៖**
  ធ្វើកម្មសិក្សា និងចុះប្រមូលព័ត៌មាន ដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ក្រោមប្រធានបទ ការគ្រប់គ្រងសំណល់រឹង របស់ក្រុមហ៊ុនស៊ីនទ្រី នៅរាជធានីភ្នំពេញ ។
- **ក្រុមហ៊ុនបានជួបប្រជុំជាមួយអង្គការ Nexus ៖**
  ដើម្បីរិះរកយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង សំណល់រឹង (សំរាម) អោយកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត ។



អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧

- ក្រុមហ៊ុនបានជួបប្រជុំជាមួយសមាគមផាងត្នោត ៖
ដើម្បីចែករំលែកចំណេះដឹងស្តីការគ្រប់គ្រងសំរាមក្នុងរាជធានីភ្នំពេញ និងរិះរកយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសំណល់រឹង (សំរាម) អោយកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។
- ក្រុមហ៊ុនបានផ្តល់ឱកាសដល់ក្រុមនិស្សិត Aisec ៖
ដើម្បីចែករំលែកចំណេះដឹងស្តីការគ្រប់គ្រងសំរាម និងជួយរៀបចំកម្មវិធីអប់រំដោយភ្ជាប់ជាមួយបទពិសោធន៍ជាក់ស្តែងដែលបានយល់ដឹងពីការសិក្សាស្រាវជ្រាវនេះដល់សហគមន៍ដែលមានវិបត្តិក្នុងការរស់នៅក្រោមបរិស្ថានដែលគ្មានជាសុខភាព។
- ក្រុមហ៊ុនបានអនុញ្ញាតអោយនិស្សិតមកពីសាកលវិទ្យាល័យភូមិមិន្ទភ្នំពេញ ៖
ធ្វើកម្មសិក្សានិងចុះប្រមូលព័ត៌មាន ដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ក្រោមប្រធានបទការវាយតម្លៃគុណភាពទឹកលេចចេញពីសំណល់នៅទីលានដង្កោ រាជធានីភ្នំពេញ ។
- ក្រុមហ៊ុនបានអនុញ្ញាត ភ្ញៀវមកពីប្រទេសជប៉ុន ៖
ដែលមានបទពិសោធន៍ពាក់ព័ន្ធការគ្រប់គ្រងសំណល់រឹង (សំរាម) និងការកែឆ្នៃសំរាម ដើម្បីធ្វើការពិភាក្សាដោះដូរបទពិសោធន៍ និងដកស្រង់ចំណុចល្អៗពីគ្នា សម្រាប់យកមកធ្វើការអភិវឌ្ឍន៍ការគ្រង់គ្រងសំណល់រឹងនៅប្រទេសកម្ពុជាយើង។
- ក្រុមហ៊ុនបានអនុញ្ញាត អោយតំណាងក្រុមហ៊ុន Bangladesh Prochemical Co., Ltd ដើម្បីធ្វើការពិភាក្សាដោះដូរបទពិសោធន៍ និងដកស្រង់ចំនុចល្អៗពីគ្នា សម្រាប់យកមកធ្វើការអភិវឌ្ឍន៍ការគ្រង់គ្រងសំណល់រឹងនៅប្រទេសកម្ពុជាយើង។
- ក្រុមហ៊ុន បានចាត់ចែងបុគ្គលិក-កម្មករធ្វើពលកម្ម ចាំងស្មៅតាមចិញ្ចើមផ្លូវ ចូកដី ប្រមូលសំរាមតាមប្រឡាយទឹក និងបោសសម្អាតតាមច្រាំងទន្លេ (មុខវាំង) បន្ថែមពីលើតួនាទីភារៈកិច្ចក្នុងគោលបំណង់ចូលរួមចំណែកលើកកំពស់អនាម័យបរិស្ថាន សុខមាលភាព សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ អោយកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។
- ក្រុមហ៊ុន បានចូលរួមប្រជុំជាមួយសាលាខណ្ឌទាំង១២ ចំនួនប្រហែល ២៣៣លើក ។

## IV. ការងារចុះត្រួតពិនិត្យ និងចរចារដោះស្រាយថ្លៃសេវាប្រមូល និងដឹកជញ្ជូនសំណល់រឹង នៅរាជធានី ភ្នំពេញ

របាយការណ៍កែសំរួល និងផ្លាស់ប្តូរប្រភេទតំលៃថ្លៃសេវាដឹកជញ្ជូនសំរាម និងសំអាតរាជធានី ចាប់ពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ រហូតដល់ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ បន្ទាប់ពីក្រុមការងារក្រុមហ៊ុនបានដោះស្រាយតវ៉ាអតិថិជន និងសំរបសំរួលជាលទ្ធផល បានផ្ញើទៅអគ្គិសនីកម្ពុជា ចំនួន ៣៥លើក រួមមាន៖

១. កិច្ចព្រមព្រៀង សរុប ៥៩៧៥
២. ផ្លាស់ប្តូរអាជីវកម្ម សរុប ៧៤០៥
៣. លុបថ្លៃសំរាម សរុប ៣១៦
៤. លំនៅដ្ឋានស្នាក់នៅធម្មតា សរុប ២០៥៣២



JAS-ANZ
អាគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧
E-mail: info@cintri.com.kh / Website: www.cintri.com.kh

## V. បញ្ហាប្រឈម

ក្នុងពេលប្រតិបត្តិការសំអាត ប្រមូល និងដឹកជញ្ជូន ក្រុមហ៊ុនបានជួបបញ្ហាលំបាកជាច្រើនក្នុងការគ្រប់គ្រងកាកសំណល់រឹងក្នុងរាជធានីភ្នំពេញអោយមានប្រសិទ្ធភាព បញ្ហាសំខាន់ៗទាំងអស់នោះរួមមានៈ

### ក. បញ្ហាលើការងារសំអាត

១. នៅមានប្រជាពលរដ្ឋ បញ្ចេញសំរាមខុសកម្មវិធីប្រមូល គ្មានការវេចខ្ចប់ មិនចម្រោះទឹកចេញ ។

២. អ្នកលក់ដូរចល័តតាមផ្លូវសាធារណៈ គ្មានការវេចខ្ចប់សំរាមរបស់ខ្លួនត្រឹមត្រូវ និងបញ្ចេញតាមទីសាធារណៈគ្មានការកំណត់ ។

៣. រថយន្តដឹកដី ដឹកខ្សាច់ ពុំបានសំអាតកង់រថយន្តអោយស្អាតមុនពេលចរាចរណ៍លើដងផ្លូវ ជាហេតុបណ្តាលអោយជាប់ដីតាមដងផ្លូវ និងខ្លះទៀតពុំមានតង់គ្របដីលើរថយន្តកត្តានេះធ្វើអោយជ្រុះដីរាយប៉ាយពេញដងផ្លូវ ។

៤. រថយន្តដឹកខ្សាច់ នៅតែបន្តជ្រុះ និងមានទឹកហៀរតាមដងផ្លូវ ។

៥. ការដ្ឋានសាងសង់មួយចំនួនធំគ្មានការវេចខ្ចប់ទុកដាក់សំភារៈ សំណល់សំណង់អោយបានត្រឹមត្រូវ នៅរាយប៉ាយពាសពេញផ្លូវ ។

### ខ. បញ្ហាលើការងារប្រមូលនិងដឹកជញ្ជូន

១. ទីលានចាក់សំរាមខណ្ឌដង្កោពិបាកចូលចាក់ និងស្ទះជាញឹកញាប់ ដែលបង្កអោយការប្រមូលសំរាមមិនបានតាមកម្មវិធី និងបង្កអោយខូចគ្រឿងក្រោម បែកកង់រថយន្តយ៉ាងដំណំ ។

២. ពេលយប់ផ្លូវមួយចំនួនងងឹត ជាហេតុធ្វើអោយការងារប្រមូលសំរាមនៅពេលយប់ជួបផលលំបាកច្រើន ។

៣. គ្មានទីតាំងសម្រាប់ផ្ទុកធុងដាំស្ទ័រ ជាផលវិបាកក្នុងការទុកដាក់សំរាមរបស់រទេះ ដែលបានប្រមូលសំរាមបញ្ចេញខុសម៉ោង រឺខុសកម្មវិធីប្រមូល និងរទេះដែលអូសសំរាមចេញពីផ្លូវជៀងហែម ។

៤. ផ្សារមួយចំនួននៅមិនមានកន្លែងទុកដាក់សំរាម និងមិនទាន់មានធុងដាំស្ទ័រសម្រាប់ផ្ទុកសំរាម (សំរាមផ្សារ) ដែលធ្វើអោយសំរាមនៅតែបន្តចោលនៅមុខផ្សាររឺផ្លូវក្បែរផ្សារ ។

៥. បញ្ហាចតរថយន្តគ្មានសណ្តាប់ធ្នាប់សងខាងផ្លូវធ្វើអោយប៉ះពាល់ ដល់ការបោសសម្អាត និងប្រមូល ។

៦. ហេដ្ឋារចនាសម្ព័ន្ធផ្លូវមួយចំនួន នៅតាមជាយក្រុងនៅមានកំរិត ដែលបង្កបញ្ហាលំបាកដល់ផ្នែកសេវាប្រមូល និងដឹកជញ្ជូនសំរាម (តូចចង្អៀត មានខ្សែភ្លើងរញ៉េរញ៉ៃ លិចទឹកនៅរដូវវស្សា ) ។

៧. ពេលយប់អ្នកបើកបរ (សំដៅដល់អ្នកចេញមកពីតាមក្លឹបផ្សេងៗ) ស្រវឹងច្រើនដែលបង្កគ្រោះថ្នាក់ដល់កម្មករ ដែលកំពុងបំរើការងារ ។

៨. ធុងសំរាម និងរទេះអូសសំរាម ដែលបានដាក់នៅតាមសួនច្បារ និងទីសាធារណៈ ត្រូវបានជនខិលខូចវាយបំផ្លាញ និងលួច ។

៩. បញ្ហាអេតចាយកាយ និងការហែកស្បោងសំរាមធ្វើអោយសំរាមរាយប៉ាយខុសសភាពដើម និងគ្មានសណ្តាប់ធ្នាប់ ។

### គ. បញ្ហាលើការបង់ថ្លៃសេវា

មានអតិថិជនមួយចំនួនមិនបានបំពេញកាតព្វកិច្ចបង់ថ្លៃសេវាបោសសម្អាត ប្រមូល និងដឹកជញ្ជូន ។

## VI. ភារទារអនុវត្តសម្រាប់ឆ្នាំ២០១៩

សម្រាប់ទិសដៅឆ្នាំ២០១៩ ក្រុមហ៊ុនមានគម្រោងសិក្សា និងអនុវត្តការងារមួយចំនួនអោយមានភាពកាន់តែប្រសើរឡើង និងដើម្បីកាត់បន្ថយបញ្ហាដែលកើតមានចំពោះមុខ ក្នុងនោះរួមមានចំនុចដូចខាងក្រោមៈ

- ធ្វើបច្ចុប្បន្នភាពធនធាន និងសំភារៈបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹង (សំរាម) អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ ។
- ស្ថាបនាប្រព័ន្ធបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹង (សំរាម) អោយកាន់តែប្រសើរឡើងថែមមួយកំរិតទៀត។
- ក្រុមហ៊ុននឹងបន្ថែមរថយន្តទំនើបសំរាប់បោស លាងសំអាតតាមដងវិថីសំខាន់ៗ ។
- បន្តដាក់សំណើជូនសាលារាជធានី ស្នើអន្តរាគមន៍ដោះស្រាយចំពោះអតិថិជនដែលខកខានមិនបានបង់ថ្លៃឈ្នួលសេវាប្រមូល ដឹកជញ្ជូនសំរាម និងសំអាតរាជធានីភ្នំពេញ ។
- ធ្វើបច្ចុប្បន្នភាពតារាងកំណត់តម្លៃសេវាសំរាមដាក់ជូនសាលារាជធានីភ្នំពេញ។
- បន្តការចុះត្រួតពិនិត្យលើភូមិសាស្ត្របោសសំអាត ប្រមូល និងដឹកជញ្ជូន ដើម្បីកែប្រែលក្ខណៈបច្ចេកទេសអោយសមស្របជាមួយទម្លាប់ប្រជាពលរដ្ឋ និងភូមិសាស្ត្រនៃសង្កាត់នីមួយៗ។
- បន្តពង្រីកតំបន់សេវាប្រមូលនៅតំបន់ជាយក្រុង។
- បន្តសហការជាមួយស្ថាប័នខាងក្រៅ ទាំងជាតិ និងអន្តរជាតិ។
- សូមស្នើសាលារាជធានី ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាមេត្តាជួយជំរុញបញ្ហាអនាម័យបរិស្ថានសំរាមបញ្ចូលទៅក្នុងកម្មវិធីអប់រំដល់សិស្សានុសិស្ស និងនិស្សិតតាមគ្រឹះស្ថានអប់រំ ។
- សូមស្នើសាលារាជធានីអនុវត្តវិធានការណែនាំ ផាកពិន័យស្របតាមអនុក្រឹត្យលេខ១១៣ ។
- មុនពិធីបុណ្យជាតិធំៗ ស្នើរាជរដ្ឋាភិបាល ក៏ដូចជាសាលារាជធានីភ្នំពេញ មេត្តាធ្វើការផ្សព្វផ្សាយអប់រំ ណែនាំដល់ទស្សនិកជន ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ស្ដីពីការទុកដាក់សំរាម និងវេចខ្ចប់ទុកដាក់សំរាមអោយបានត្រឹមត្រូវ ។ ទ.

នាយកគ្រប់គ្រងក្រុមហ៊ុន

ស៊ីនទ្រី (ខេមបូឌា)
CINTRI (CAMBODIA) Ltd.
អគ្គនាយកដ្ឋានរាជធានីភ្នំពេញ

សេង_សារី



អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣ ៧២៦ ១៦២ ទូរសារ : (០២៣ ៧២៦ ១៦៧
E-mail: info@cintri.com.kh //Website www.cintri.com.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនស៊ីនទ្រី (ខេមបូឌា)
CINTRI (CAMBODIA) LTD.

ថ្ងៃទី...១៧...ខែ...មីនា...ឆ្នាំ២០១៧

លេខ...០១៤៧/១៧ ស.ទ.ខ

# រចនាសម្ព័ន្ធសង្ខេបរបស់ក្រុមហ៊ុន




ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) CINTRI (CAMBODIA) Ltd. ចុះបញ្ជីពាណិជ្ជកម្មរាជធានីភ្នំពេញ

សេង សារី

អគារលេខ ៤៤២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១២០ ទូរស័ព្ទ : (០២៣) ៧២៦ ១៦២ ទូរសារ : (០២៣) ៧២៦ ១៦៧
E-mail : info@cintri.com.kh / Website : www.cintri.com.kh